ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីក្នុងឃុំនគរភាស
# ស្រុកអង្គរជុំ ខេត្តសៀមរាប
# ២០០៩-២០២២




មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តសៀមរាប

សមាសភាគរៀបចំដែនដី

Danida Danish International Development Assistance

DANIDA/ DFID/NZaid

# មាតិកា


**ពាក្យអក្សរកាត់** ---------- ១

**អារម្ភកថា** ---------- ២

**សេចក្តីផ្តើម** ---------- ៤

**ជំពូក១**

**ពត៌មាន និង ទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់** ---------- ៥

១.១ ស្ថានភាពទូទៅនៃឃុំនគរភាស ---------- ៥

១.១.១ ទីតាំងរដ្ឋបាល ---------- ៥

១.១.២ ប្រជាសាស្ត្រ ---------- ៦

១.១.៣ ស្ថានភាពសេដ្ឋកិច្ច ---------- ៨

១.១.៤ ស្ថានភាពអប់រំ និងសិក្សាធិការ ---------- ១១

១.១.៥ ស្ថានភាពសុខាភិបាល ---------- ១៤

១.២ ស្ថានភាពភូមិសាស្ត្រ ---------- ១៦

១.២.១ ទីតាំងភូមិសាស្ត្រ ---------- ១៦

១.២.២ អាកាសធាតុ ---------- ១៧

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូនៈ ---------- ១៨

១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន ---------- ១៩

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ---------- ២០

១.៣.២ ស្ថានភាពគ្រប់គ្រង និងកាន់កាប់ដី ---------- ២១

១.៣.៣ ផលិតកម្មកសិកម្ម ---------- ២៤

*១.៣.៣.១ ផលិតកម្មដំណាំស្បៀង* ---------- ២៤

*១.៣.៣.២ ផលិតកម្មដំណាំរួមផ្សំ* ---------- ២៦

*១.៣.៣.៣ ផលិតកម្មដំណាំឧស្សាហកម្ម* ---------- ២៨

១.៣.៤ ធនធានធម្មជាតិ ---------- ២៨

*១.៣.៤.១ ធនធានព្រៃឈើ* ---------- ២៨

*១.៣.៤.២ ធនធានជលផល -------------------------------------------------- ២៩*
១.៣.៥ ធនធានរ៉ែ---------------------------------------------------- ២៩
១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល ------------------------------------------ ២៩
១.៤.១ ទីផ្សារ និងតំលៃកសិផល ផលអនុផលព្រៃឈើ និង ផលនេសាទ------------------ ២៩
១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល ---------------------------------------- ៣០

## ជំពូក២

**ការវិភាគពីសក្តានុពល ឧបសគ្គ និងតំរូវការសំរាប់អនាគត**--------------------------- ៣១
២.១ ចំណោលប្រជារាស្ត្រគិតដល់ឆ្នាំ ២០២២------------------------------------------ ៣១
២.១.១ អត្រាកំណើន ---------------------------------------------------- ៣១
២.១.២ ចំណោលប្រជាសាស្ត្រ ------------------------------------------------ ៣១
២.២ តម្រូវការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំ ------------------------------------ ៣៣
២.៣ តម្រូវការសំរាប់អនាគត------------------------------------------------- ៣៧
២.៣.១ ដីលំនៅដ្ឋាន ---------------------------------------------------- ៣៧
២.៣.២ ដីកសិកម្ម------------------------------------------------------ ៣៧
២.៣.៣ ដីព្រៃឈើ ------------------------------------------------------ ៣៨
២.៣.៤ ធនធានទឹក------------------------------------------------------ ៣៨
២.៣.៥ ហេដ្ឋារចនាសម្ពន្ធ័ និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត ---------------------- ៣៩
២.៣.៦ ឧស្សាហកម្ម ---------------------------------------------------- ៤១
២.៤ តំបន់រសើប------------------------------------------------------- ៤១
២.៥ ការប្រឈម និង ឧបសគ្គ----------------------------------------------- ៤៣
២.៥.១ ការប្រឈមដោយធម្មជាតិ---------------------------------------------- ៤៦
២.៥.២ ការប្រឈមដោយការអភិវឌ្ឍន៍ដែលពុំមាន ចិរភាព (គ្មានផែនការទុក ជាមុន) ------------------ ៤៦
២.៦ ជាឱកាស -------------------------------------------------------- ៤៦
២.៦.១ ដោយអំណោយផលធម្មជាតិ --------------------------------------------- ៤៦
២.៦.២ ដោយបច្ចេកទេសថ្មី ------------------------------------------------- ៤៧
២.៦.៣ ដោយគំរោងវិនិយោគ------------------------------------------------- ៤៧

**ជំពូក៣**

**ផែនការប្រើប្រាស់ដីនាពេលអនាគតឆ្នាំ២០០៩_២០២២** -------------------------------- ៤៨

៣.១ ការប្រើប្រាស់ដីសំរាប់ពេលអនាគត---------------------------------------------------- ៤៨

៣.២ បញ្ញត្តិលើការប្រើប្រាស់ដី ------------------------------------------------------------ ៤៩

៣.៣ ការវាយតំលៃនៃការប្រើប្រាស់ដី ------------------------------------------------------- ៥២

៣.៤ ដំណោះស្រាយផ្សេងៗក្នុងករណីខ្វះខាតដី ------------------------------------------------ ៥២

៣.៥ កត្តាចាំបាច់សំរាប់ធានានិរន្តរ៍ភាព---------------------------------------------------- ៥៣

៣.៥.១ កត្តាចាំបាច់សំរាប់ធានានិរន្តរភាព ------------------------------------------------ ៥៣

៣.៥.២ គំរោងគាំទ្រចាំបាច់នានាសំរាប់ការអភិវឌ្ឍន៏ប្រកបដោយចិរភាព ---------------------------- ៥៣

៣.៦ ការសន្និដ្ឋានជារួមលើផែនការប្រើប្រាស់នាពេលអនាគត -------------------------------------- ៥៣

# បញ្ជីតារាង ដ្យាក្រាម និង ផែនទី


ផែនទីរដ្ឋបាលឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប ------------------------------------------- ៦
តារាងទី១: ស្ថិតិចំនួនប្រជាជនតាមអាយុក្នុងឃុំ ឆ្នាំ២០០៨------------------------------------------- ៧
ដ្យាក្រាមទី១: ស្ថិតិចំនួនប្រជាជនតាមអាយុក្នុងឃុំ ឆ្នាំ២០០៨ ------------------------------------- ៧
តារាងទី២: មុខរបរប្រជាពលរដ្ឋក្នុងឃុំ ------------------------------------------------------- ៩
ដ្យាក្រាមទី២: ភាគរយមុខរបរ ក្នុងឃុំ -----------------------------------------------------១០
តារាងទី៣: ចំណាត់ថ្នាក់លំនៅដ្ឋាន-----------------------------------------------------------១០
តារាងទី៤: ទិន្នផលស្រូវ និង ដំណាំរួមផ្សំ ឃុំនគរភាស------------------------------------------១១
តារាងទី៦ : ស្ថិតិតាមអាយុដែលបានចូលរៀន ---------------------------------------------------១២
តារាងទី៧ : អត្រាប្រជាជនមិនចេះអក្សរ តាមអាយុ-------------------------------------------------១៣
តារាងទី៨ : ចំនួនកុមារ និង ស្ត្រី ដែលបានទទួលសេវាកម្មសុខភាព ---------------------------------១៤
តារាងទី៩: ប្រភេទទឹកប្រើប្រាស់ប្រចាំគ្រួសារ ---------------------------------------------------១៤
ដ្យាក្រាមទី៣: ភាគរយគ្រួសារប្រើប្រាស់ប្រភពទឹកស្អាត ------------------------------------------១៥
តារាងទី១០: បរិមាណទឹកភ្លៀងប្រចាំឆ្នាំ-----------------------------------------------------------១៧
ដ្យាក្រាមទី៤: របាយទឹកភ្លៀងប្រចាំឆ្នាំ ---------------------------------------------------------១៨
តារាងទី១១: ចំណាត់ថ្នាក់ការប្រើប្រាស់ដីលំអិតក្នុងឃុំនគរភាស -----------------------------------២០
ដ្យាក្រាមទី៥ : ការប្រៀបធៀប ការប្រើប្រាស់ដីក្នុងឃុំបច្ចុប្បន្ន-----------------------------------២០
ផែនទីប្រើប្រាស់ដីលំអិតឃុំ -------------------------------------------------------------------២២
ផែនទីប្រើប្រាស់ដីសាមញ្ញឃុំ -------------------------------------------------------------------២៣
តារាងទី១២: ចំណាត់ថ្នាក់ការប្រើប្រាស់ដីសាមញ្ញ ក្នុងឃុំនគរភាស---------------------------------២៤
តារាងទី១៣: ផលិតភាពដំណាំស្រូវ ក្នុងឃុំ-------------------------------------------------------២៥
តារាងទី១៤: គ្រួសារទំហំដីស្រែតិច និង តំលៃស្រូវ -----------------------------------------------២៦
តារាងទី១៥: ផលិតភាពដំណាំរួមផ្សំ----------------------------------------------------------------២៧
តារាងទី១៦: គ្រួសារទំហំដីចំការតិច និង ការប្រើប្រាស់ជីគីមី, ថ្នាំគីមី--------------------------------២៧
តារាងទី១៧: ស្ថិតិប្រជាជនតាមឆ្នាំ-------------------------------------------------------------------៣១
តារាងទី១៨: កំនើតប្រជាជនតាមអាយុ និង បំរែបំរួលកំនើនប្រជាជន ឆ្នាំ២០២២ -------------------------៣២
ដ្យាក្រាមទី៦: ប្រៀបធៀបកំនើតប្រជាជនតាមអាយុ ក្នុងឆ្នាំ២០០៨ និងអនាគតឆ្នាំ២០២២ ---------------- ៣៣
តារាងទី១៩: ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជំរើសនៃការប្រើប្រាស់ដីធ្លីអនាគត -------------------------៣៤

តារាងទី២០: តម្រូវការដីសំរាប់លំនៅដ្ឋាន ឆ្នាំ២០២២ ----------------------------------------------------------------------------------------------------------------------------------------------------- ៣៧
តារាងទី២១: តម្រូវការដីសំរាប់កសិកម្ម ឆ្នាំ២០២២ ------------------------------------------------------------------------------------------------------------------------------------------------------ ៣៧
តារាងទី២២: ផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ ------------------------------------------------------------------------------------------------ ៣៩
តារាងទី២៣: កំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០២២ -------------------------------------------------------------------------------------------------- ៤០
ផែនទីតំបន់រសើបឃុំនគរភាស -------------------------------------------------------------------------------------------------------------------------------------------------------------------- ៤២
តារាងទី២៤: បញ្ហាប្រឈម និងសក្តានុពល (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ) ------------------------------------------------------------------------- ៤៤
ផែនទីបញ្ហា មូលហេតុ ដំណោះស្រាយ ឃុំនគរភាស ---------------------------------------------------------------------------------------------------------------------------------------- ៤៥
តារាងទី២៥: តម្រូវការនៃការប្រើប្រាស់ដី អនាគតឆ្នាំ២០២២ ----------------------------------------------------------------------------------------------------------------------------- ៤៨

## ឧបសម្ពន្ធ័

ឧបសម្ពន្ធ័ ទី១: តារាងបញ្ជីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋក្នុងឃុំ-------------------------------------------------------------------------------------------------------- ៥៥
ឧបសម្ពន្ធ័ ទី២: តារាងផែនការអនាគត ១៥ឆ្នាំ------------------------------------------------------------------------------------------------------------------------------------------------------------------ ៥៥
ឧបសម្ពន្ធ័ ទី៣: ផែនទីប្រើប្រាស់ដីអនាគតឆ្នាំ២០០៩-២០២២ ----------------------------------------------------------------------------------------------------------------------------------- ៥៥
ឧបសម្ពន្ធ័ ទី៤: ផែនទីគំរបព្រៃឈើ ឆ្នាំ២០០២ និង ផ្ទៃដី --------------------------------------------------------------------------------------------------------------------------------------- ៥៥
ឧបសម្ពន្ធ័ ទី៥: រូបថតសកម្មភាពការងារចុះមូលដ្ឋាន ------------------------------------------------------------------------------------------------------------------------------------------------ ៥៥

# ពាក្យអក្សរកាត់

| | |
|---|---|
| ក្រ.ដ.ន.ស<br>MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>Ministry of Land Management, Urban Planning and Construction |
| មន្ទីរ.ដ.ន.ស.ស<br>PDLMUPCC | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី<br>Provincial Department of Land Management, Urban Planning  Construction and Cadastre |
| ការិ.ដ.ន.ស.ភ<br>DOLMUPC | ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល<br>District Office of Land Management, Urban Planning, Construction and Land Titling |
| គ.គ្រ.ដ.រ.ជ<br>NSLMC | គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ជាតិ<br>National State Land Management Committee |
| គ.គ្រ.ដ.រ.ខ<br>PSLMC | គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត<br>Provincial State Land Management Committee |
| ក.ក.ដ.រ.ស<br>DSLWG | ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ<br>District State Land Working Group |
| គ.ស.ស.ជ<br>NSLMC | គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ<br>National Social Land Concession Committee |
| គ.ប.ដ.រ.ខ<br>PLUAC | គណៈកម្មការប្រើប្រាស់ និងបែងចែកដីថ្នាក់រាជធានី ខេត្ត<br>Provincial Land Use and Allocation Committee |
| ក.ក.ស<br>DWG | ក្រុមការងារថ្នាក់ក្រុង ស្រុក ខ័ណ្ឌ<br>District Working Group |
| ក.ស.ផ.ប.ជ<br>N-LUP Team | ក្រុមការងារសម្របសម្រួលផែនការប្រើប្រាស់ដីថ្នាក់ជាតិ<br>National Land Use Planning Team |
| ក.ស.ផ.ប.ខ<br>P-LUP Team | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត<br>Provincial Land Use Planning Team |
| ក.ស.ផ.ប.ស្រ<br>D-LUP Team | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ<br>District Land Use Planning Team |
| DANIDA/DFID/NZAids | ម្ចាស់ជំនួយ Danish International Development Assistance/Department for International Development/ Newzealand Aids |
| ក.គ.ក.វ.វ<br>PSDD | កម្មវិធីគាំទ្រដល់កំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ<br>Program to Support Decentralization and Deconcentration Reform |
| កបឃ<br>CC | ក្រុមប្រឹក្សាឃុំ សង្កាត់<br>Commune Council |
| គផថ<br>PBC | គណៈកម្មការផែនការ និងថវិកាឃុំ សង្កាត់<br>Planning and Budgeting Committee |
| ផអឃ<br>CDP | ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់<br>Commun Development Plan |
| កវឃ<br>CIP | កម្មវិធីវិនិយោគឃុំ សង្កាត់<br>Commune Investment Program |
| ក.ស.ខ<br>PFT | ក្រុមសម្របសម្រួលថ្នាក់រាជធានី ខេត្ត<br>Provincial Facilitation Team |
| ក.ស.ស្រ<br>DFT | ក្រុមសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ<br>District Facilitation Team |

# អារម្ភកថា

ឯកសារស្តីអំពីការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប រយៈពេលពីឆ្នាំ២០០៩-២០២២ ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាឃុំនគរភាស ដោយមានការចូលរួមពីគណៈកម្មការផែនការ និងថវិកាថ្នាក់ឃុំ និងប្រជាពលរដ្ឋនៅមូលដ្ឋានគ្រប់ភូមិ ។ក្រោមការជួយសំរបសំរួលពីក្រុមការងាររៀបចំផែនការប្រើប្រាស់ដីស្រុកអង្គរជុំ ( D-LUP ) និង មានការគាំទ្របច្ចេកទេសពីក្រុមសំរបសំរួលរៀបចំផែនការប្រើប្រាស់ដី-ខេត្តសៀមរាប ( P-LUP )។ ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ ត្រូវបានគាំទ្រ និង ប្រឹក្សាយោបល់ពីក្រុមការងារ ថ្នាក់ជាតិអនុសមាសភាគរៀបចំដែនដី (Land Management Sub-Component) របស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមកម្មវិធីជំនួយឥតសំណង របស់ភ្នាក់ងារ អភិវឌ្ឍន៏ DANIDA/DFID/NZAid ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រង ធនធានធម្មជាតិ និងជីវភាពរស់នៅ តាមរយៈ ស្ថានទូតដាណឺម៉ាក ប្រចាំនៅក្នុងប្រទេសកម្ពុជា ។

ផែនការប្រើប្រាស់ដីនៅក្នុងឃុំដែលបានកសាងឡើងនេះមានគោលដៅកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋក្រីក្រក្នុងឃុំ ដែលភាគច្រើនរស់នៅដោយពឹងផ្អែកលើធនធានធម្មជាតិនៅក្នុងឃុំរបស់ខ្លួន ហើយមានសារៈសំខាន់ណាស់ ក្នុងការជួយចង្អុលបង្ហាញទិសដល់ការអភិវឌ្ឍន៍ឃុំ ដើម្បីឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ និងបង្កើនកំរិតជីវភាពរស់នៅ ឱ្យកាន់តែល្អប្រសើរឡើង ។

ក្រុមប្រឹក្សាឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដែលបានគាំទ្រផ្នែកគោលនយោបាយ និងបច្ចេកទេស និងភ្នាក់ងារអភិវឌ្ឍន៏ DANIDA/DFID/NZAid ដែលបានផ្តល់ថវិកា សំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំនគរភាសនេះ ។ ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះក្រុមសំរបសំរួលរៀបចំផែនការប្រើប្រាស់ដីធ្លីស្រុកអង្គរជុំ និង ក្រុមសំរបសំរួលរៀបចំផែនការប្រើប្រាស់ដីធ្លីមន្ទីរ ដ.ន.ស.ស ខេត្តសៀមរាប ដែលបានជួយគាំទ្របច្ចេកទេសក្នុងការអនុវត្តន៍ជាក់ស្តែង ។ ដើម្បីឱ្យការរៀបចំផែនការប្រើប្រាស់ដីនេះលេចចេញជារូបរាងឡើងពិតប្រាកដ ហើយការរៀបចំផែនការនេះក៏មានការចូលរួមពីមន្ទីរ ដែលជាស្ថាប័នពាក់ព័ន្ធនានាជុំវិញខេត្ត ជាពិសេសអង្គភាពផ្នែក រដ្ឋបាលមូលដ្ឋាន អង្គភាពផ្នែកហិរញ្ញវត្ថុ និង អង្គភាពផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល របស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៏ជនបទខេត្តសៀមរាប និងរួមទាំងមន្ទីរគ្រប់វិស័យ ដូចជាមន្ទីរកសិកម្ម មន្ទីរផែនការ មន្ទីរបរិស្ថាន និងរដ្ឋបាលព្រៃឈើ ។ ល ។

ជាទីបញ្ចប់ យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ នឹងបានយល់ដឹង និងស្វែងយល់អំពីស្ថានភាពជាក់ស្តែង តម្រូវការពិតប្រាកដ បញ្ហាប្រឈមទាំងឡាយ និងឧបសគ្គផ្សេងៗ ដែលជាកត្តារាំងស្ទះដល់ដំណើរការអភិវឌ្ឍន៏ឃុំ ពាក់ព័ន្ធនឹងការប្រើប្រាស់ដីនៅក្នុងឃុំក៏ដូចជាការពាក់ព័ន្ធរបស់ប្រជាពលរដ្ឋក្នុងឃុំនគរភាសហើយម្យ៉ាងទៀតនឹងបង្ហាញនូវទឹកចិត្តសប្បុរសធម៌ដ៏ថ្លៃថ្លា តាមរយៈការចូលរួមផ្តល់នូវគំនិតស្ថាបនាសំរាប់ការអភិវឌ្ឍន៏ឃុំ ឬផ្តល់ជាសំភារៈ និងថវិកា សំរាប់គាំទ្រដល់ដំណើរការរៀបចំ

ផែនការប្រើប្រាស់ដីនៅក្នុងឃុំនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍមូលដ្ឋាន លើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ស្របតាម គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ។

ឃុំនគរភាស, ថ្ងៃទី...11...ខែ...12.......ឆ្នាំ ២០០៩

មេឃុំ នគរភាស

ថោង ឆន់

# សេចក្តីផ្តើម

គំរោងអភិវឌ្ឍន៍នានាជាច្រើនកំពុងដំណើរការនៅក្នុងឃុំ ដែលមានគោលដៅរួមមួយគឺ អភិវឌ្ឍន៍ ឃុំ ដោយមានការគិតគូ យ៉ាងម៉ត់ចត់ ទៅលើការអភិរក្ស និងការធ្វើសមាហរណកម្មផែនការ។ កត្តាអភិវឌ្ឍន៍ទាំងឡាយ ត្រូវតែផ្សារភ្ជាប់ទៅនឹងការអភិរក្សធនធានធម្មជាតិ និង បរិស្ថាន។ ប៉ុន្តែការអភិវឌ្ឍន៍ប្រឈមនឹងបញ្ហាមួយចំនួនក្នុងការគ្រប់គ្រងធនធាន ធម្មជាតិ ចំនួនដូចជា ការទន្ទ្រានលើតំបន់ការពារ ការសាងសង់នៅលើទីតាំងមិនសមស្រប ការកាប់ឈើខុសច្បាប់ ការរំលោភយកដី និងការលុបចោលនូវសិទ្ធប្រើប្រាស់ ធនធានធម្មជាតិ។ អាស្រ័យហេតុនេះ ការគិតគូរទុកជាមុន នូវគំរោងផែនការប្រើប្រាស់ដីក្នុងឃុំ ឬ ឃុំមានផែនការប្រើប្រាស់ដីអនាគត គឺជាត្រីវិស័យសំរាប់ តំរង់ទីសអភិវឌ្ឍន៍នានា ក្នុងទស្សនវិស័យវែងឆ្ងាយ។

ការកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ ជាការធ្វើសមាហរណកម្មផែនការសំខាន់មួយក្នុងឃុំសំរាប់អភិវឌ្ឍន៍ឃុំឱ្យមានចីរភាព ដូចជាការប្រើប្រាស់ដីក្នុងឃុំបច្ចុបន្ន និងការរៀបចំផែនការប្រើប្រាស់ដីទៅអនាគត ស្របតាមផែនការអភិវឌ្ឍន៍ឃុំ CDP និង កម្មវិធីវិនិយោគឃុំ CIP ។ គោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាល ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ឆ្នាំ២០០១ ច្បាប់ភូមិបាលឆ្នាំ២០០១ ច្បាប់គ្រប់គ្រងព្រៃឈើ ច្បាប់គ្រប់គ្រងធនធានទឹក ច្បាប់ពាក់ព័ន្ធផ្សេងៗមួយចំនួនទៀតដែលមានក្នុងព្រះរាជាណាចក្រកម្ពុជាអនុក្រឹត្យលេខ៧២អនក្រ-បក.ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដី នៅក្នុងឃុំ-សង្កាត់ អនុក្រឹត្រពាក់ព័ន្ធនានា និងសេចក្តីណែនាំនានារបស់រាជរដ្ឋាភិបាល គឺជាមូលដ្ឋានយ៉ាងសំខាន់បំផុតសំរាប់ ក្រុមប្រឹក្សាឃុំរៀបចំកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំរបស់ខ្លួន ដោយមានផែនការអភិវឌ្ឍន៍ច្បាស់លាស់។

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំនគរភាស ជាការរៀបចំផែនការមួយក្នុងចំណោមឃុំគោលដៅបីក្នុងស្រុក អង្គរជុំ ខេត្តសៀមរាប។ ផែនការនេះមានគោលបំណងចំបង គឺជាការចូលរួមចំណែក កាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ភូមិ-ឃុំ ស្របតាមគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ និងគោលនយោបាយចតុកោណ របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេសលើកស្ទួយសេដ្ឋកិច្ចនិង កំរិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ។

គោលបំណងចំបងនៃ ផែនការប្រើប្រាស់ដីនៅក្នុង ឃុំនគរភាស នេះ គឺដើម្បីគាំទ្រដល់ដំណើរការកសាង ផែនការអភិវឌ្ឍន៍ឃុំ និងសំរាប់ប្រើប្រាស់ក្នុងការរៀបចំអភិវឌ្ឍន៍ឃុំទាំងមូលឱ្យចំទិសដៅ ប្រកបដោយនិរន្តរភាព និងឱ្យ ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ សំដៅ ពង្រឹងអភិបាល កិច្ចល្អរបស់រាជរដ្ឋាភិបាល ដើម្បីលើកស្ទួយសេដ្ឋកិច្ច កំរិតជីវភាពរស់នៅ និងភាពសុខដុមរមនា របស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ ឡើង។

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ នគរភាស អាចដំណើរការទៅបានល្អ និងទទួលបានជោគជ័យ ក៏ដោយសារមាន ការចូលរួមគាំទ្រពី មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប និង ស្ថាប័នពាក់ព័ន្ធនានា ដូចជា មន្ទីរផែនការ មន្ទីរអប់រំយុវជន និង កីឡា មន្ទីរកសិកម្ម រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល មន្ទីរឧតុនិយមការិយាល័យ PSDD និង អាជ្ញាធរ មូលដ្ឋានគ្រប់លំដាប់ថ្នាក់ ។

# ជំពូក១

# ពត៌មាន និង ទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់

## ១.១ ស្ថានភាពទូទៅនៃឃុំនគរភាស

ឃុំនគរភាស មានទីតាំងស្ថិតនៅប៉ែកខាងត្បូងឈៀងខាងកើតទីរួមស្រុកអង្គរជុំមានចំងាយ៨ គម។ ឃុំនេះមានទីតាំង នៅក្នុងភូមិល្បើកជាប់ដងផ្លូវលំ ឃុំនគរភាសមានផ្ទៃដីសរុបស្មើរនឹង ៥៤៦៦,១២ ហិកតា ។

ប្រជាជនឃុំនគរភាសទាំងមូល ស្ទើរតែ ១០០ភាគរយ ជាអ្នកប្រកបមុខរបរធ្វើស្រែចំការ ជាចំបង និង រួមផ្សំជាមួយនឹងការចិញ្ចឹមសត្វដូចជាគោក្របីដើម្បីបំរើជាកម្លាំងអូសទាញក្នុងការធ្វើស្រែ ចំការតែប៉ុណ្ណោះ ហើយ ក៏មានការចិញ្ចឹម ជ្រូក មាន់ ទា តាមលក្ខណៈគ្រួសារ និងពុំមានការចិញ្ចឹមសត្វរូបភាពជាសហគមន៏ ជាកសិដ្ឋាន មានលក្ខណៈជាឯកជន រឺរបស់រដ្ឋនៅឡើយ ។

រវាងភូមិមួយទៅភូមិមួយ ដោយមានផ្លូវលំតភ្ជាប់គ្នាខ្វាត់ខ្វែង ដែលផ្លូវជាប្រភេទដីក្រហម និង ផ្លូវលំដីស ហើយការធ្វើដំណើរនៅរដូវវស្សា ក៏មានជួបការលំបាកខ្លះៗ ដោយសារទឹកជំនន់កាត់ដាច់ផ្លូវ ។

### ១.១.១ ទីតាំងរដ្ឋបាល

**ព្រំប្រទល់ឃុំ :**

- -ខាងជើងទល់និង ឃុំដូនពេង ( ស្រុកអង្គរជុំ)
- -ខាងត្បូងទល់និង ឃុំត្រីញ័រ ( ស្រុកពួក)
- -ខាងកើតទល់និង ឃុំគោកដូង ( ស្រុកអង្គរជុំ) និងឃុំជប់តាត្រាវ ( ស្រុកអង្គរធំ)
- -ខាងលិចទល់និង ឃុំតាសោម ( ស្រុកអង្គរជុំ)

**ឃុំមានចំនួនភូមិ សរុប ១០ ភូមិ គឺ :**

| | |
|---|---|
| ១-ភូមិ នគរភាស ១ | ៦-ភូមិ រមៀត |
| ៥-ភូមិ នគរភាស ២ | ៧-ភូមិ ទន្លេសរ |
| ២-ភូមិ គោកថ្មី | ៨-ភូមិ ពង្រ |
| ៣-ភូមិ ល្បើក | ៩-ភូមិ ជំពូង |
| ៤-ភូមិ សំបួរ | ១០-ភូមិ កុក |

**ផែនទីរដ្ឋបាលឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប**




## ១.១.២ ប្រជាសាស្ត្រ

ប្រជាពលរដ្ឋក្នុងឃុំ ស្ទើតែ ១00% ជាជនជាតិខ្មែរ ប្រកាន់ សាសនាព្រះពុទ្ធ ។ប្រជាជនក្នុងឃុំ មានមុខរបរជាចំបងគឺ ធ្វើស្រែចំការ ដាំដំណាំរួមផ្សំ និងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងលក់ដូរបន្ទាប់បន្សំដើម្បី បំពេញបន្ថែម ជីវភាពរស់នៅក្នុងគ្រួសាររបស់ខ្លួន ។

ប្រជាជនដែលមានវ័យពេញកម្លាំង ប្រហែល ២0-៣0%បានធ្វើចំណាកស្រុកក្រោយរដូវដកស្ទូងស្រូវវស្សា ទៅធ្វើជាកម្មករស៊ីឈ្នួលធ្វើជាងសំណង់ នៅខេត្តសៀមរាប ។

## តារាងទី១: ស្ថិតិចំនួនប្រជាជនតាមអាយុក្នុងឃុំ ឆ្នាំ២០០៨

| អាយុ | ប្រុស (នាក់) | ស្រី (នាក់) | សរុប (នាក់) |
|---|---|---|---|
| ក្រោម ២ ឆ្នាំ | ៣១៥ | ២៧២ | ៥៨៧ |
| ៣-៤ ឆ្នាំ | ២០៧ | ២២៦ | ៤៣៣ |
| ៥ ឆ្នាំ | ១៧៣ | ១៨២ | ៣៥៥ |
| ៦ ឆ្នាំ | ១៧៩ | ១៥៨ | ៣៣៧ |
| ៧-១១ ឆ្នាំ | ៥៣៤ | ៤១១ | ៩៤៥ |
| ១២-១៤ ឆ្នាំ | ៤០១ | ៣២៦ | ៧២៧ |
| ១៥-១៧ ឆ្នាំ | ៣៥៨ | ៣៨១ | ៧៣៩ |
| ១៨-២៤ ឆ្នាំ | ៥៤៣ | ៥៥២ | ១០៩៥ |
| ២៥-៣៥ ឆ្នាំ | ៥៥០ | ៦៨៧ | ១២៣៧ |
| ៣៦-៤៥ ឆ្នាំ | ៤៥៧ | ៥៦៣ | ១០២០ |
| ៤៦-៦០ ឆ្នាំ | ៣៥៦ | ៣៨៦ | ៧៤២ |
| ៦១ ឆ្នាំ ឡើង | ១៧០ | ១៤៧ | ៣១៧ |
| **ប្រជាជនសរុប(នាក់)** | ៤២៤៣ | ៤២៩១ | ៨៥៣៤ |

ប្រភពទិន្នន័យ:មន្ទីរផែនការខេត្តសៀមរាប២០០៨

## ដ្យាក្រាមទី១: ស្ថិតិចំនួនប្រជាជនតាមអាយុក្នុងឃុំ ឆ្នាំ២០០៨




ប្រភពទិន្នន័យ:មន្ទីរផែនការខេត្តសៀមរាប

**ចំនួនប្រជាជនក្នុងឆ្នាំ ២០០៨**

| | |
|---|---|
| -ប្រជាជនសរុប | : ៨ ៥៣៤នាក់ ស្រី : ៤ ២៩១នាក់ |
| -ចំនួនគ្រួសារសរុប | : ១ ៤៨៣ គ្រួសារ |
| -ផ្ទៃដីសរុប | : ៥៤៦៦,១២ ហិកតា |
| -សមាជិកគ្រួសារជាមធ្យម | : ៥,៧ នាក់ |
| -របាយដង់ស៊ីតេ | : ១៥៦ នាក់/គីឡូម៉ែត្រ ។ |

## ១.១.៣ ស្ថានភាពសេដ្ឋកិច្ច

ប្រភពចំណូលជាចំបងគឺ ផលស្រូវ និងចំណូលពីធ្វើចំការឪឡឹក និងពោត ក្រោយការច្រូតកាត់រួចមួយផ្នែកទៀតជាចំណូលបន្ទាប់បន្សំ ការចិញ្ចឹមសត្វ មាន់ ទា ជ្រូក ។ កំរិតជីវភាពរស់នៅចំណូលប្រចាំថ្ងៃស្មើ ៨២១/១ថ្ងៃ និងប្រចាំឆ្នាំស្មើ ៣0.0000៛ ។ ការចំណាយប្រចាំឆ្នាំ (ស្បៀងអាហារ, សំលៀកបំពាក់, ឧបករណ៍ប្រើប្រាស់, សំភារៈសិក្សា, ថ្នាំសង្កូវ, និងចំណាយផ្សេងៗស្មើ ៤0.0000៛ ។ ស្ថានភាពបំណុលសរុប ១៤៣.១៩៧.000៛ និងអត្រាការប្រាក់មាន ECLIDA 2,8%, AMK 3%, ធនាគារភូមិ ៣% , ក្រេឌីត ៣% , លំនៅដ្ឋាន ១,៥% , ស្ថាបនា ៣%, សីលា ៣%, ធនាគារស្រូវ ៣% ។

ចំណូលពីប្រភពផ្សេងៗបានមកពីប្រាក់ VIB = ២៥,១៤៧,00៛00 ដែលមិនយកការប្រាក់ គឺជាប្រាក់ឱ្យជាក្រុមសមាគមន៍ ។



រូបភាពទី១:សកម្មភាពដាំដំណាំបន្លែ

## តារាងទី២: មុខរបរប្រជាពលរដ្ឋក្នុងឃុំ

| ល.រ | ប្រភេទមុខរបរសំខាន់ | ចំនួនគ្រួសារ | |
|---|---|---|---|
| | | ចំនួនគ្រួសារ | ភាគរយ % |
| **១.មុខរបរកសិកម្មជាចំបង** | | ១៤០៧ | ៩៤,៨៨% |
| **១.១ ដំណាំស្រូវជាចំបង** | | ១៤០៧ | ៩៤,៨៨% |
| | ធ្វើស្រែជាចំបង | ១៤០៧ | ៩៤,៨៨% |
| | ធ្វើចំការស្រូវជាចំបង | 0 | 0,00% |
| **១.២ ចំការជាចំបង** | | 0 | 0,00% |
| | ដំណាំរយៈពេលយូរអង្វែង | 0 | 0,00% |
| | ដំណាំរយៈពេលខ្លី | 0 | 0,00% |
| | ដំណាំបន្លែ | 0 | 0,00% |
| **១.៣ នេសាទជាចំបង** | | 0 | 0,00% |
| **១.៤ ចិញ្ចឹមសត្វជាចំបង** | | 0 | 0,00% |
| **១.៥ អនុផលព្រៃឈើ** | | 0 | 0,00% |
| **២. សិប្បកម្មជាចំបង** | | 0 | 0,00% |
| ២.១ សិប្បកម្មគ្រឿងសង្ហារឹមអំពីឈើ | | 0 | 0,00% |
| ២.២ សិប្បកម្មផលិតអំពីដែក អាលុយមីញ៉ូម កញ្ចក់ | | 0 | 0,00% |
| ២.៣ សិប្បកម្មផលិតគ្រឿងបរិភោគ | | 0 | 0,00% |
| ២.៤ សិប្បកម្មផលិត សំបកកង់ម៉ូតូ | | 0 | 0,00% |
| ២.៥ សិប្បកម្មត្បាញរវៃ | | 0 | 0,00% |
| ២.៦ សិប្បកម្មផលិតផ្សេងៗ | | 0 | 0,00% |
| **៣. សេវាកម្មជាចំបង** | | ៣ | 0,២០% |
| ៣.១ ជំនួញលក់ដូរផ្សេងៗ | | 0 | 0,00% |
| ៣.២ ជាងជួសជុល | | 0 | 0,00% |
| ៣.៣ ដឹកជញ្ជូន | | 0 | 0,00% |
| ៣.៤ សេវាកម្មផ្សេងៗ | | ៣០ | 0,២០% |
| **៤. មុខរបរមិនច្បាស់លាស់** | | ៧៣ | ៤,៩២% |
| | | **ចំនួនមនុស្សសរុប(នាក់)** | **ស្រី** |
| **៥. មន្ត្រីរាជការ** | | ៣២ | - |
| **៦. បុគ្គលិក កម្មករ ក្រុមហ៊ុនឯកជន** | | ១៣ | - |
| **៧. ចំណាកស្រុក ប្រកបមុខរបរផ្សេងៗ** | | ២២៦ | ១១៤ |
| ៧.១ ក្រុមហ៊ុន រោងចក្រ ក្រៅស្រុក | | ៣៧ | ២៨ |
| ៧.២ មុខរបរមិនច្បាស់លាស់ | | ១៨៩ | ៨៦ |

| | | |
|---|---|---|
| ៨. ការខារសន្លមស៊ីវិល | ៤៥ | ២៩ |
| ៩. មនុស្សអាយុ ១៨-៦០ឆ្នាំដែលគ្មានការងារ ធ្វើពិតប្រាកដ និងទៀងទាត់ | ៣៣ | ១៥ |

ប្រភពទិន្នន័យ:មន្ទីរផែនការខេត្តសៀមរាប

## ដ្យាក្រាមទី២: ភាគរយមុខរបរ ក្នុងឃុំ




## តារាងទី៣: ចំណាត់ថ្នាក់លំនៅដ្ឋាន

| ប្រភេទលំនៅដ្ឋាន | ចំនួនខ្នងផ្ទះ | ភាគរយ |
|---|---|---|
| ចំនួនផ្ទះប្រក់ស្លឹក ស្បូវ | ៧៥៥ | ៥១,៦៤% |
| ចំនួនផ្ទះប្រក់សង្កសី ហ្វីប្រូស៊ីម៉ង់ត៍ | ៣៧៧ | ២៥,៧៩% |
| ចំនួនផ្ទះប្រក់ក្បឿង | ៣៣០ | ២២,៥៧% |
| ចំនួនផ្ទះថ្ម ផ្ទះថ្ម( មួយគ្រួសាររស់នៅ) | ០ | ០ |

ប្រភពទិន្នន័យ: សៀវភៅស្ថិតិឃុំ

**តារាងទី៤: ទិន្នផលស្រូវ និង ដំណាំរួមផ្សំ ឃុំនគរភាស**

| ល.រ | ឈ្មោះដំណាំ | ផ្ទៃដី (ហត) | ទិន្នផលមធ្យម (ត/ហត) | ទិន្នផលសរុប (ត) | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ស្រូវស្រាល | ៦១០ | ១.៣ | | វស្សា |
| ២ | ស្រូវកណ្តាល | ១១២០ | ១.៣ | | វស្សា |
| ៣ | ស្រូវធ្ងន់ | ២៦០ | ១.៣ | | វស្សា |
| ៤ | ពោត | ២ | ៣.៥០ | | វស្សានិងប្រាំង |
| ៥ | ដំឡូងមី | ២ | ១២.៣០ | | វស្សានិងប្រាំង |
| ៦ | ដំឡូងជ្វា | - | - | | |
| ៧ | បន្លែគ្រប់មុខ | ៤ | ៧.១០ | | វស្សានិងប្រាំង |
| ៨ | អំពៅ | ១ | ១៦.៤០ | | វស្សានិងប្រាំង |
| ៩ | ល្ង | - | - | | |
| ១០ | សណ្តែកដី | - | - | | |
| ១១ | សណ្តែកសៀង | - | - | | |
| ១២ | សណ្តែកបាយ | ០.៥ | ០.៩០ | | វស្សានិងប្រាំង |
| ១៣ | ឪឡឹក | ៥ | ៨.៥០ | | វស្សានិងប្រាំង |
| ១៤ | ល្ពៅងប្រេង | - | - | | |

ប្រភពទិន្នន័យ: មន្ទីរកសិកម្មខេត្តសៀមរាប

## ១.១.៤ ស្ថានភាពអប់រំ និងសិក្សាធិការ

ទីតាំងអាគារសិក្សាមានកំរិតអនុវិទ្យាល័យ និងបឋមសិក្សា ដែលស្ថិតនៅជិតជាមួយសិស្សានុសិស្ស បង្កការងាយស្រួលឱ្យពួកគេមានវ័យចូលសាលាបានគ្រប់ៗគ្នា នៅក្នុងឃុំនេះមានចែកជាកំរិតសាលាដូចតទៅ :

-ចំនួនសាលាអនុវិទ្យាល័យ ១ខ្នង ចំនួន ២បន្ទប់

-សាលាបឋមសិក្សាមានចំនួន ៧ខ្នង ចំនួន ២៨បន្ទប់

-គ្រូសរុប ៣០នាក់ ស្រី ១០នាក់

-សិស្សសរុប ១៧៤៤នាក់ ស្រី ៨៥០នាក់

-អត្រាក្មេងគ្រប់អាយុដែលមិនបានចូលរៀន

-អត្រាអក្ខរកម្ម មនុស្សចាស់ គ្មាន

-នៅតាមបណ្តាអាគារសិក្សាទាំងអស់ទូទាំងឃុំមានវិសាលភាពសមល្មមមានទីធ្លា និងបរិស្ថានធម្មជាតិល្អ ទៅអនាគត បើមានគំរោងសាងសង់អាគារបន្ថែមសាលាមួយចំនួន អាចមានលទ្ធភាពសាងសង់បានមួយ ចំនួនទៀត ដីធ្លីនៅពេលនេះមិនអាចដាក់សំណង់បាន តែអាចបង្កើនជាចំនួនជាវបាន ព្រោះយើងត្រូវគិតនៅការ រៀបចំឱ្យទីធ្លាមានសោភ័ណ្ឌភាព និងបរិស្ថានជុំវិញឱ្យល្អប្រសើរ ។

-សិស្សានុសិស្ស បើផ្អែកទៅតាមស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារ ពួកគេមានលទ្ធភាពសិក្សាបានត្រឹមថ្នាក់ ទី១២ ដូចជាមកទល់ឆ្នាំនេះ សិស្សដែលបានបញ្ចប់ថ្នាក់ទី១២ ស្មើ ០,៣៤% ព្រោះពួកគេគ្មានមធ្យោបាយ និងថវិកាដើម្បីបន្តការសិក្សាដល់កំរិតបញ្ចប់មានចំនួនតូចណាស់ ដែលពួកគេអាចបន្តការសិក្សានៅមហាវិទ្យាល័យ ឬសាលាបច្ចេកទេសបណ្តុះបណ្តាលវិជ្ជាជីវៈ នោះគឺអាស្រ័យទៅដោយស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ ។

## តារាងទី៥ ៖ ប្រភេទសាលារៀនឃុំនគរភាស

| ប្រភេទសាលារៀន | ចំនួនសាលា | ចំនួនបន្ទប់ | ចំនួនថ្នាក់រៀន |
|---|---|---|---|
| មត្តេយ្យសហគមន៍ | ០ | ០ | ០ |
| មត្តេយ្យរដ្ឋ | ៤ | ៤ | ៤ |
| សាលាបឋមសិក្សា | ៧ | ២៨ | ៣៦ |
| អនុវិទ្យាល័យ | ១ | ២ | ៣ |
| វិទ្យាល័យ | ០ | ០ | ០ |
| សាលាឯកជន ត្រឹមវិទ្យាល័យចុះក្រោម | ០ | ០ | ០ |

ប្រភពទិន្នន័យៈមន្ទីរអប់រំខេត្តសៀមរាប

## តារាងទី៦ ៖ ស្ថិតិតាមអាយុដែលបានចូលរៀន

| អាយុ | ចំនួនសិស្ស ដែលបានចូលរៀន | | | ចំនួនសិស្ស ដែលមិនបានចូលរៀន | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ៣-៥ឆ្នាំ | | | ០ | - | - | - |
| ៦ឆ្នាំ | ១២៧ | ១៤២ | **២៦៩** | ៥២ | ១៦ | **៦៨** |
| ៧-១១ឆ្នាំ | ៤៣៤ | ៣៦៤ | **៧៩៨** | ១០០ | ៤៧ | **១៤៧** |
| ១២-១៤ឆ្នាំ | ២៨៩ | ២៦៦ | **៥៥៥** | ១១២ | ៦០ | **១៧២** |
| ១៥-១៧ឆ្នាំ | ២១២ | ១៦៣ | **៣៧៥** | - | - | - |
| ១៨-២៤ឆ្នាំ | ៩២ | ៧៦ | **១៦៨** | - | - | - |
| **សរុប** | ១១៥៤ | ១០១១ | **២១៦៥** | ២៦៤ | ១២៣ | **៣៨៧** |

## តារាងទី៧ ៈ អត្រាប្រជាជនមិនចេះអក្សរ តាមអាយុ

| អាយុ | ចំនួនប្រជាជន ដែលមិនចេះអក្សរ | | | |
|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ភាគរយ |
| ១៥-១៧ឆ្នាំ | ៦២ | ៦២ | **១២៤** | **១៦,៧៨%** |
| ១៨-២៤ឆ្នាំ | ១៣៥ | ១៤៨ | **២៨៣** | **២៥,៨៤%** |
| ២៥-៣៥ឆ្នាំ | ២១៣ | ២២៣ | **៤៣៦** | |
| ៣៦-៤៥ឆ្នាំ | ១៥០ | ២២២ | **៣៧២** | |
| ៤៦-៦០ឆ្នាំ | ១២៧ | ១៦៩ | **២៩៦** | |

ប្រភពទិន្នន័យៈ មន្ទីរអប់រំខេត្តសៀមរាប

**ចំងាយធៀបពីចំនុចកណ្តាលភូមិ មកសាលារៀន**

| | សាលាបឋម | អនុវិទ្យាល័យ | វិទ្យាល័យ |
|---|---|---|---|
| **ចំងាយ គិតជា គីឡូម៉ែត្រ** | ០,៧ | ៤,២ | ១១,១ |




រូបភាពទី២ៈសាលាបឋមសិក្សា

## ១.១.៥ ស្ថានភាពសុខាភិបាល

-មានអាគារមណ្ឌលសុខភាពមួយខ្នង ដែលបើកបំរើការព្យាបាលដល់ប្រជាជន និងការសង្គ្រោះ ក្នុងករណីដែលកើតមានស្ថានភាពជំងឺផ្សេងៗ ។

-ចំនួនគ្រូពេទ្យ ៤នាក់ ឆ្មប ១នាក់

-ប្រភេទជំងឺដែលកាចសាហាវ ឬជាជំងឺឆ្លង ហើយកើតមានជាញឹកញាប់ គឺជំងឺគ្រុនឈាម និងគ្រុនចាញ់ ។

-ធ្វើការចាក់ថ្នាំបង្ការជំងឺ ៧មុខ និងអាហារូបត្ថម្ភ ម្សៅពោត, ប្រេងឆា, អង្ករ ។

-ករណីជំងឺធ្ងន់ធ្ងរ ការបញ្ជូនជំងឺដោយមធ្យោបាយផ្ទាល់ខ្លួន មកមណ្ឌលសុខភាព ព្រោះមណ្ឌលសុខភាព ស្ថិតនៅជិតពួកគាត់ ឯការបញ្ជូនទៅមន្ទីរពេទ្យបង្អែកក៏ជាមធ្យោបាយផ្ទាល់ខ្លួនទាំងការចំណាយចាយវាយផ្សេងៗ។

**តារាងទី៨ : ចំនួនកុមារ និង ស្ត្រី ដែលបានទទួលសេវាកម្មសុខភាព**

| ក្រុមកុមារ និង ស្ត្រី | សេវាកម្មសុខភាព | | | | |
|---|---|---|---|---|---|
| | ឆ្មបបុរាណ | ភាគរយ | ឆ្មបពេទ្យ | ភាគរយ | ចាក់ថ្នាំបង្ការគ្រប់ចំនួន |
| ចំនួនស្ត្រីដែលបានឆ្លងទន្លេ | ៦៧ | ៣៣,៣៣% | ១៣៤ | ៦៦,៦៧% | - |
| ចំនួនមរណៈភាពមាតាបន្ទាប់ពីសំរាល កូនចន្លោះ០-១ខែ | ០ | | ០ | | - |
| ចំនួនទារកដែលកើតរស់ | ៦៧ | | ១៣៤ | | - |
| ចំនួនទារកស្លាប់អាយុក្រោម១ខែ | ០ | | ៣ | | - |
| ចំនួនកុមារស្លាប់ អាយុពី១ខែ ដល់ ៥ឆ្នាំ | ៤ | | ០ | | - |
| ចំនួនកុមាអាយុ៩-១២ខែបានទទួល ថ្នាំបង្ការគ្រប់មុខ | - | | - | | ៨៤ |

ប្រភពទិន្នន័យ: មន្ទីរផែនការខេត្តសៀមរាប

**តារាងទី៩: ប្រភេទទឹកប្រើប្រាស់ប្រចាំគ្រួសារ**

| ប្រភេទប្រភពទឹក | ចំនួន | ភាគរយគ្រួសារប្រើប្រាស់ |
|---|---|---|
| អណ្តូងស្នប់ឬចំរុះ | ៤៦ | ១៦,៦៧% |
| អណ្តូងលូ | ១២៥ | ៤៥,២៩% |
| អណ្តូងដៃមិនដាក់លូ ឬរវៀបអិដ្ឋ | ១០៥ | ៣៨,០៤% |
| ស្រះទឹកធម្មតា | ០ | ០ |
| ស្រះទឹកមានដាក់ចំរោះ | ០ | ០ |

ប្រភពទិន្នន័យ: មន្ទីរផែនការខេត្តសៀមរាប



រូបភាពទី៣:មណ្ឌលសុខភាពនគរភាស

| **ស្ថានភាពអនាម័យ និង ការប្រើប្រាស់ទឹក:** | **ភាគរយ** |
|---|---|
| -គ្រួសារ ទទួលទានទឹក មិនស្អាត ( ពុំមានចំរោះ ឬដាំឱ្យពុះ ) | ៦២,៣៧% |
| -គ្រួសារ ទទួលទានទឹក ស្អាត ( អណ្តូងស្នប់ ឬចំរោះ ឬដាំឱ្យពុះ ) | ៣៧,៦៣% |
| -គ្រួសារទទួលទានទឹក ដោយដាំទឹកឱ្យពុះ: | ២,៥៦% |
| -គ្រួសារទទួលទានទឹកដោយ ឧបករណ៍ចំរោះទឹក : | ៧,៨២% |
| -គ្រួសារពុំមានបង្គន់អនាម័យប្រើប្រាស់ | ៨៥,០៣% |

**ដ្យាក្រាមទី៣: ភាគរយគ្រួសារប្រើប្រាស់ប្រភពទឹកស្អាត**




ប្រភពទិន្នន័យ: មន្ទីរផែនការខេត្តសៀមរាប

## ១.២ ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

ឃុំនគរភាស ជាទីតាំងមានលក្ខណៈភូមិសាស្ត្រសម្បូរទៅដោយផ្ទៃដីកសិកម្មស្មើ ៩០% នៅមានសេសសល់ ជាប្រភេទ ដីរិចរិលស្មើ ២% ជាស្ថានភាពដីខ្ពង់រាប ងាយទទួលយកនៅភាពរាំងស្ងួតជាខ្លាំង ពីស្ថានភាពទឹកភ្លៀង ប្រែប្រួល ហើយ ក៏ពុំមាន លទ្ធភាពពង្រីកផ្ទៃដីកសិកម្មបានទៀតឡើយ ។

-ស្ថានភាពដី ជាវាលទំនាប ហើយជាទូទៅនៅមានប្រើប្រាស់ដីក្នុងការធ្វើកសិកម្មជាច្រើនឆ្នាំមកហើយ ។

-ប្រភពទឹក គឺទទួលយកបានពីអំណោយផលទឹកភ្លៀង ក្នុងការជួយអោយការលូតលាស់ទៅលើផលិតផល គ្រប់ប្រភេទ ព្រោះឃុំនេះពុំមានលទ្ធភាពក្នុងការធ្វើប្រព័ន្ធធារាសាស្ត្រខ្នាតធំបានឡើយ ។ ប៉ុន្តែវាក៏មានសក្តានុពល មួយ ចំនួនដែលអាចទាញយកមកប្រើប្រាស់បានគឺ មានបឹង, ត្រពាំង, អូរ ដែលអាចស្តុកទឹកបាន តែពុំមានលទ្ធភាព ធ្វើការ អភិវឌ្ឍន៍ ។

-ប្រភេទដី ល្បាយខ្សាច់, គុណភាពដី, ខ្សោះជីជាតិ ២/៣, សភាពដីមានភាពហួតហែង បើមានជួបនៅ បញ្ហា រាំងស្ងួត ពុំមានលទ្ធភាពជួយអន្តរាគមន៍នូវផលដំណាំទាំងនោះបានឡើយ ព្រោះគ្មានប្រភពទឹក ជាពិសេសលើ ដំណាំស្រូវ ដែលជាស្បៀងចាំបាច់បំផុត ។

ស្ថានភាពដី ជាវាលទំនាប ហើយជាទូទៅនៅមានប្រើប្រាស់ដីក្នុងការធ្វើកសិកម្មជាច្រើនឆ្នាំមកហើយ ។ ប្រភពទឹក គឺទទួលយកបានពីអំណោយផលទឹកភ្លៀង ក្នុងការជួយអោយការលូតលាស់ទៅលើផលិតផល គ្រប់ប្រភេទ ព្រោះឃុំនេះ ពុំមានលទ្ធភាពក្នុងការធ្វើប្រព័ន្ធធារាសាស្ត្រខ្នាតធំបានឡើយ ។ ប៉ុន្តែវាក៏មានសក្តានុពល មួយចំនួនដែលអាចទាញយកមក ប្រើប្រាស់បានគឺ មានបឹង, ត្រពាំង, អូរ ដែលអាចស្តុកទឹកបាន តែពុំមានលទ្ធភាព ធ្វើការអភិវឌ្ឍន៍ ។

ប្រភេទដី ល្បាយខ្សាច់, គុណភាពដី, ខ្សោះជីជាតិ ២/៣ សភាពដីមានភាពហួតហែង បើមានជួបនៅ បញ្ហា រាំងស្ងួត ពុំមានលទ្ធភាពជួយអន្តរាគមន៍នូវផលដំណាំទាំងនោះបានឡើយ ព្រោះគ្មានប្រភពទឹក ជាពិសេសលើ ដំណាំស្រូវ ដែលជាស្បៀងចាំបាច់បំផុត ។

ស្ថានភាពដីភាគច្រើនជាខ្ពង់រាប ដោយនៅផ្នែកខាងជើងស្ថិតក្នុងរយៈកំពស់ ២៦-៤៧ម៉ែត្រ និង ផ្នែក ខាងត្បូង រយៈកំពស់១២-២៦ម៉ែត្រ ធៀបនឹងនីវ៉ូទឹកសមុទ្រ (ផែនទីប្រើប្រាស់ដី) ។អាស្រ័យដោយតំបន់នេះជាខ្ពង់រាប និង ខ្វះប្រព័ន្ធ ធារាសាស្ត្រ ដែលជាហេតុ ធ្វើអោយការធ្វើស្រែ ចំការ នៅក្នុងឃុំនេះ ងាយរងគ្រោះ នឹងបញ្ហាខ្វះទឹកស្រោចស្រព ការធ្វើ កសិកម្ម គឺពឹងផ្អែកទៅ លើល័ក្ខខ័ណ្ឌធម្មជាតិទាំងស្រុង ។

ផ្អែកតាមលក្ខណៈបច្ចេកទេសកសិកម្ម គុណភាពដីជាតិដី ក្នុងតំបន់នេះ មានលក្ខណៈល្អបង្គួរសំរាប់ការបង្កបង្កើន ផល ។ បើតាមការពិនិត្យ ក្សេត្របរិស្ថាន និងលក្ខណៈដំណាំអាចចែកតំបន់ជាពីរផ្នែក គឺ : ១-តំបន់ប៉ែកខាងត្បូងឃុំ ដីមាន គុណភាពមធ្យម មានលក្ខណៈទំនាប សមស្របសំរាប់ស្រែវស្សានិង ដំណាំបន្លែ ២-តំបន់ប៉ែកខាងជើងឃុំ ដីមាន

គុណភាពជីជាតិមានគុណភាពខ្ពស់ សមស្របសំរាប់ដំណាំចំការឈើហូបផ្លែ និង ដំណាំកសិឧស្សាហកម្ម ឧ.ពោត សណ្តែកល្ង អំពៅ ។ល។

ប្រភពទឹកគឺបានមកពីអណ្តូង និងស្រះឯកជន ក្រៅពីនេះនៅក្នុងឃុំក៏មានបឹងត្រពាំងធំៗច្រើនដែលអាចជាប្រភពទឹក ដែលអាចសាងសង់ជាអាងស្តុកទឹក ប៉ុន្តែឃុំពុំមានលទ្ធភាព ដូចជាថវិកា និងបច្ចេកទេស ដើម្បីសាងសង់ និងស្តារប្រពន្ធ័ស្រោចស្រព្វនេះឡើងវិញទេ គឺត្រូវការចាំបាច់ការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាល និងអង្គការផ្សេងៗ ។

## **១.២.២ អាកាសធាតុ**

នៅក្នុងឃុំនគរភាស ក៏ដូចជានៅក្នុងស្រុកអង្គរជុំទាំងមូល កំពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំ ១៣៤៥,៩មម ដោយគិតក្នុងរដូវវស្សាពីខែឧសភា ដល់ខែតុលា ។

-រយៈពេលរដូវប្រាំងគិតពីខែវិច្ឆិកា ដល់ខែមេសា ។

-សីតុណ្ហភាពជាមធ្យម ២៨ °C តែនៅខែ មេសា សីតុណ្ហភាពអាចឡើងដល់ ៣៩ °C ។

-សំណើមអាកាស ពី ៦៥ភាគរយ ដល់ ៩៥ ភាគរយ សំណើមខ្លាំងគឺនៅរដូវវស្សា ។

-ក្នុងឃុំមានល្បឿនខ្យល់ធម្មតា ពុំសូវមានព្យុះធំៗ ដែលបង្កអន្តរាយដល់ផ្ទះសំបែង និងដំណាំផ្សេងៗ ឡើយ ។

**តារាងទី១០: បរិមាណទឹកភ្លៀងប្រចាំឆ្នាំ**

| ខែ | មក រា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណទឹកភ្លៀង | ៣,៥០ | 0,0 | ៣៤,0 | ៥៦,៨ | ១៧៧,៨ | ១៣៥,៩ | ១0៣,៤ | ១៩៦,៩ | ២៧៤,៥ | ៣00,0 | ៦៣,១ | 0,0 |
| ចំនួនថ្ងៃមានភ្លៀងធ្លាក់ | ១,00 | 0,0 | ៤,00 | ៧,00 | ១១,00 | ១0,00 | ៨,00 | ១៦,00 | ១២,00 | ១៦,00 | ៦,00 | 0,0 |
| បរិមាណទឹកភ្លៀងសរុប ប្រចាំឆ្នាំ ២00៨ : ១៣៤៥,៩ មីលីម៉ែត្រ | | | | | | | | | | | | |
| មានភ្លៀងធ្លាក់ ប្រចាំឆ្នាំ ២00៨ ចំនួន : ៩១ ថ្ងៃ | | | | | | | | | | | | |

ប្រភពទិន្នន័យៈមន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប

## ដ្យាក្រាមទី៤: របាយទឹកភ្លៀងប្រចាំឆ្នាំ




ប្រភពទិន្នន័យ:មន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប

### ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូនៈ

ការប្រាស្រយ័ទំនាក់ទំនងពីឃុំទៅឃុំផ្សេងទៀត និងពីភូមិទៅភូមិក្នុងឃុំ ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ការដឹកជញ្ជូនផលិតផលកសិកម្ម និងសំភារៈនានា តាមផ្លូវលំដីក្រហម សរុបប្រវែង ៦,០៥ គីឡូម៉ែត្រ និង ផ្លូវដីសមាន ប្រវែង ៣៧,០៨ គីឡូម៉ែត្រ ផ្លូវធម្មតាមិនទាន់លើកដី និង ផ្លូវរទេះប្រវែងសរុប ៧១,៣៧គីឡូម៉ែត្រ។ ឃុំបានប្រើប្រាស់បណ្តាញផ្លូវទាំងនេះភ្ជាប់រវាងភូមិទាំង១០ របស់ឃុំ ទៅទីប្រជុំជន និងទីរួមស្រុក ។ ប្រវែងផ្លូវសរុប ១១៤,៥០ គីឡូម៉ែត្រ (ទិន្នន័យផែនទីបច្ចុប្បន្នភាព២០០៩) ។ ឃុំពុំមានផ្សារនៅក្នុងឃុំសំរាប់ដោះដូរផលិតកសិកម្ម និង ទំនិញផ្សេងៗទេ។ ប្រជាជនត្រូវធ្វើដំណើរចំងាយប្រហែល ១៣គីឡូម៉ែត្រដើម្បីដឹកទំនិញ ឬ ទិញសំភារៈផ្សេងៗ ដែលជា តំរូវការ របស់ពួកគាត់ នៅផ្សារស្រុកពួក ។ នៅរដូវវស្សាមានការលំបាកក្នុងការធ្វើដំណើរ ដោយសារ ភ្លៀងធ្លាក់ច្រើនធ្វើឱ្យផ្លូវ គ្រួស ក្រហមត្រូវបានដាច់ដោយ កន្លែងៗ ដោយសារទឹក ជំនន់មកពីតំបន់ខ្ពង់រាបខាងលើ ។

**មធ្យោបាយដឹកជញ្ជូន ក្នុងឃុំ**

| | |
|---|---|
| ▪ សមាមាត្រគ្រួសារធៀបនិងកង់/កង់រឺម៉ក | ១,២៦ |
| ▪ សមាមាត្រគ្រួសារធៀបនិងរទេះគោ | ២,០៦ |
| ▪ សមាមាត្រគ្រួសារធៀបនិងម៉ូតូ/ម៉ូតូរឺម៉ក | ៤,៥២ |
| ▪ សមាមាត្រគ្រួសារធៀបនិងម៉ូតូកង់បី(ត្រីចក្រយាន្តយន្ត) | ០ |
| ▪ សមាមាត្រគ្រួសារធៀបនិងត្រាក់ទ័រ(ភ្ជួរស្រែ) | ០ |
| ▪ សមាមាត្រគ្រួសារធៀបនិងគោយន្ត(ភ្ជួរស្រែ) | ២៤៧,២ |

- សមាមាត្រគ្រួសារផៀបនិងរថយន្ត ២១១,៩
- សមាមាត្រគ្រួសារផៀបនិងរថយន្តកែច្នៃក្នុងស្រុក ២៩៦,៦
- សមាមាត្រគ្រួសារផៀបនិងរថយន្តដឹកជញ្ជូនទំនិញ ៧៤១,៥
- សមាមាត្រគ្រួសារផៀបនិងរថយន្តឈ្នួលដឹកអ្នកដំណើរ 0
- សមាមាត្រគ្រួសារផៀបនិងរថយន្តសំរាប់ប្រើប្រាស់ក្នុងគ្រួសារ 0
- សមាមាត្រគ្រួសារផៀបនិងទូកចែវ/អុំ 0
- សមាមាត្រគ្រួសារផៀបនិងទូកម៉ាស៊ីននិងកាណូត 0
- សមាមាត្រគ្រួសារផៀបនិងទូកម៉ាស៊ីននិងកាណូតសំរាប់នេសាទ 0
- សមាមាត្រគ្រួសារផៀបនិងទូកម៉ាស៊ីននិងកាណូតសំរាប់ដឹកអ្នកដំណើរ 0
- សមាមាត្រគ្រួសារផៀបនិងទូកម៉ាស៊ីននិងកាណូតសំរាប់ដឹកទំនិញ 0



រូបភាពទី៤: ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

ស្ថានភាពនៃការកាន់កាប់ និងប្រើប្រាស់ដី ចែកជា តំបន់កសិកម្ម លំនៅដ្ឋាន តំបន់ការពារព្រៃឈើ និង សហគមន៍ព្រៃឈើ ។ ការប្រើប្រាស់ដីទាំងនេះ គឺត្រូវបានធ្វើការកំនត់ និងការព្រមព្រៀង នៅថ្នាក់ឃុំ និងភូមិ ដើម្បីធ្វើការការពារធនធានធម្មជាតិ គ្រប់គ្រងថែរក្សាបឹងបួ ត្រពាំងធម្មជាតិ ដីរដ្ឋ ដើម្បីការពារ និងបំរើអោយផលប្រយោជន៍ជាសាធារណៈរបស់ឃុំ ។

## ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ផ្ទៃដីកសិកម្ម សំរាប់ធ្វើស្រែចំការ របស់ប្រជាពលរដ្ឋក្នុងឃុំនាពេលបច្ចុប្បន្ន អាចផ្គត់ផ្គង់ និងធានាបាននូវជីវភាព របស់ប្រជាពលរដ្ឋ ។ ប៉ុន្តែសំរាប់ ដល់ឆ្នាំ២០២២តម្រូវការដីកើនឡើង ស្របតាមកំណើនប្រជាជន គឺអាចមានការខ្វះខាត ដីសំរាប់ធ្វើស្រែ ចំការ ដូចនេះត្រូវការបន្ថែមទៀតនូវដីសំរាប់សម្បទាន សេដ្ឋកិច្ច និងសង្គមកិច្ច ។

**តារាងទី១១: ចំណាត់ថ្នាក់ការប្រើប្រាស់ដីលំអិតក្នុងឃុំនគរភាស**

| ប្រភេទនៃការប្រើប្រាស់ដី | ក្រឡាផ្ទៃ (ហិកតា) | បរិយាយ |
|---|---|---|
| ដីលំនៅដ្ឋានភូមិ | ៣៧៩.៧ | ដីសំរាប់លំនៅដ្ឋាន មានលាយដីសួនដំណាំហូបផ្លែ ឬ ចំការក្បែរផ្ទះ |
| ដីស្រូវវស្សា | ៣៩៥០ | ដីស្រែ ដែលពឹងពាក់ទឹកភ្លៀងទាំងស្រុក |
| ដីព្រៃផ្សេងៗ | ៥៧៨ | គំរបព្រៃឈើ ឆ្នាំ២០០២ |
| វាលស្មៅលិចទឹក | ៣.១១ | ដីវាលស្មៅលិចទឹក នៅតាមតំបន់បឹង ត្រពាំង ធំៗ ឬ នៅវាលទំនាបលិចទឹក |
| ចំការបោះបង់ដុះព្រៃគម្ពោត | ៥៣១.៣៨ | ដីចំការចាស់ដែលមានដុះព្រៃគម្ពោតទាបៗ |
| បឹង | ១៨.១០ | ដីដែលមានប្រភពទឹកបឹងធំ ភាគច្រើនតាមទីវាល |
| ត្រពាំង | ៥.៨៣ | ដីដែលមានប្រភពទឹកត្រពាំង ភាគច្រើនតាមភូមិ |
| **ផ្ទៃដីសរុប** | **៥៤៦៦.១២ហិកតា** | |

ប្រភពទិន្នន័យ: ផែនទីប្រើប្រាស់បច្ចុប្បន្នភាពឃុំ ២០០៩

**ដ្យាក្រាមទី៥ : ការប្រៀបធៀប ការប្រើប្រាស់ដីក្នុងឃុំបច្ចុប្បន្ន**




ប្រភពទិន្នន័យ: ផែនទីប្រើប្រាស់បច្ចុប្បន្នភាពឃុំ ២០០៩

## ១.៣.២ ស្ថានភាពគ្រប់គ្រង និងកាន់កាប់ដី

ក្រោមការតិតគូរយ៉ាងហ្មត់ចត់នៅថ្នាក់ឃុំ និងដោយមានការចូលរួមពីគ្រប់ភូមិក្នុងឃុំនគរភាស ស្ថានភាពកាន់កាប់ និងប្រើប្រាស់ដីត្រូវបានធ្វើការវិភាគ ដោយបានកំណត់ជាតំបន់ប្រើប្រាស់សំរាប់លំនៅដ្ឋាន ស្រែចំការ និងតំបន់ការពារ ដែលមាន ដូចជាតំបន់ដែលត្រូវរក្សាទុកជាតំបន់ដីព្រៃឈើរបស់រដ្ឋ (នៅលើផែនទីលំអិតរបស់ឃុំ) ។ រីឯការកាន់កាប់ដី ដោយខុសច្បាប់ ក៏មានខ្លះដែរ ដូចជាការរានដី ការកាប់ព្រៃយកដីរដ្ឋ ធ្វើជាកម្មសិទ្ធផ្ទាល់ខ្លួន ហើយលក់បន្ត ឱ្យឈ្មួញ ។ ភាពមិន ស្រុះស្រួលរបស់ប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ និងការរំលោភបំពានគ្នាទៅវិញទៅមក នៅរដូវ ធ្វើស្រែ ចំការ ។ តែទោះ ជាយ៉ាងណា ឃុំបានដោះស្រាយ ទប់ស្កាត់ជាបន្តបន្ទាប់ និងមិនអនុញ្ញាត ចេញលិខិត បញ្ជាក់ជូន អ្នកខុសច្បាប់ គឺអនុវត្ត យ៉ាងតឹងរឹងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ឱ្យបានជាដាចខាត ។

បញ្ហាទំនាស់ក្នុងការប្រើប្រាស់ដីភាគច្រើនទាក់ទងនឹងទំនាស់ព្រំ ប្រទល់រវាងស្រុក និងស្រុក ដែលជាបញ្ហាមួយ ស្មុគស្មាញដែលពុំទាន់បានធ្វើការដោះស្រាយឡើយសមត្ថកិច្ចស្រុកទាំងពីរពុំទាន់មានលទ្ធភាពធ្វើការសំរបសំរួលគ្នាដោយ យល់ព្រមលើចំនុចរួម និង ប្រើប្រាស់ ផែនទីណាជាគោលការណ៍នៅឡើយ ។

# ផែនទីប្រើប្រាស់ដីលំអិត ឃុំនគរភាស ឆ្នាំ ២០០៩

## Detail Land Use Map of Norkpr Phease Commune for Year 2009 (170105)




បានឃើញ និងបញ្ជាក់ថា

ផែនទីនេះពិតជាត្រូវបានពិនិត្យ និងរៀបចំដោយគណៈកម្មការ

ផែនការ និងថវិកា និង ក្រុមប្រឹក្សាឃុំប្រាកដមែន។

នគរភាស, ថ្ងៃទី............ខែ.........ឆ្នាំ.......

មេឃុំនគរភាស

**ប្រព័ន្ធកូអរដោនេ**

| | | |
|---|---|---|
| ចំណោលផែនទី | : | UTM |
| តំបន់ទី | : | 48N |
| ទិន្នន័យយោង | : | WGS |
| អេលីបសូអ៊ីត | : | Everest |

**ប្រភពទិន្នន័យ :**

- នាយកដ្ឋានភូមិសាស្រ

១- ទិន្នន័យគោល : ផ្លូវទឹក, ផ្លូវថ្នល់, ព្រំប្រទល់រដ្ឋបាល, ទីតាំងភូមិ ឃុំ/សង្កាត់ ស្រុក/ខ័ណ្ឌ ខេត្ត/ក្រុង (២០០៣)

២- ទិន្នន័យប្រើប្រាស់ដី : (២០០៣)

- តំបន់ការពារបរិស្ថាន ក្រសួងបរិស្ថាន

**បញ្ជាក់ :**

១- ពត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងនៅថ្នាក់ជាតិ និងត្រូវបានកែសំរួលដោយបានការចូលរួមពីសហគមន៍មូលដ្ឋាន។

២- ខ្សែព្រំប្រទល់រដ្ឋបាល ដែលបានស្តែងនៅលើផែនទីនេះ ពុំអាចយកជាការបានទេ។

**៣- ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ កញ្ញា ឆ្នាំ ២០០៩**

# ផែនទីប្រើប្រាស់ដីសាមញ្ញឃុំនគរភាស

## Symplify Land Use Map of Norkor Pheas Commune (170105)



**តារាងទី១២:   ចំណាត់ថ្នាក់ការប្រើប្រាស់ដីសាមញ្ញ  ក្នុងឃុំនគរភាស**

| **ប្រភេទនៃការប្រើប្រាស់ដី** | **ក្រឡាផ្ទៃ (ហិកតា)** | **បរិយាយ** |
|---|---|---|
| ដីលំនៅដ្ឋាននិង ហេដ្ឋារចនាសម្ព័ន្ធ | ៣៧៩.៧ | រួមបញ្ចូលដីលំនៅដ្ឋាន, ទីប្រជុំជន, ហេដ្ឋារចនាសម្ព័ន្ធ, វាលយន្តហោះ, ដីកប់ខ្មោច |
| ដី កសិកម្ម | ៣៩៥០ | រួមបញ្ចូលដីស្រែវស្សានិងប្រាំង, ដីចំការ និង កសិកម្មពនេចរ |
| ដីព្រៃឈើ | ៩៧៨ | គំរបព្រៃឈើឆ្នាំ២០០២ |
| វាលស្មៅ | ៩៣៤.៤៩ | ចំការបោះបង់ដុះស្មៅ, វាលស្មៅ, វាលភក់ |
| ប្រភពទឹក | ២៣.៩៣ | ដីដែលមានប្រភពទឹកបឹង ធំៗ , ត្រពាំង |
| **ផ្ទៃដីសរុប** | **៥៤៦៦,១២ ហិកតា** | |

ប្រភពទិន្នន័យៈ ផែនទីប្រើប្រាស់បច្ចុប្បន្នភាពឃុំ ២០០៩

## ១.៣.៣ ផលិតកម្មកសិកម្ម

### ១.៣.៣.១ ផលិតកម្មដំណាំស្រូវ

ដោយសារតែស្ថានភាពទឹកដីឃុំនគរភាស ប្រជាកសិករជាអ្នកស្រែចំការ គឺជាមុខសញ្ញាជាចម្បង ហើយ ដែលពេលនេះ ប្រជាជនពុំមានដីស្រែពង្រីកបន្តទៀតទេ ផ្ទៃដីស្រែដែលមានស្រាប់នេះមានសភាពខ្សោះជីជាតិពីរ មួយឆ្នាំទៅមួយឆ្នាំមាន ការថយ ចុះទិន្នផល និងអាចឈានទៅប្រើប្រាស់ជីគីមី ដើម្បីបង្កើនផលដំណាំ ។

-ដីស្រូវវស្សា ៣៥% ជាប្រភេទដីល្បាយខ្សាច់

-ស្ថានភាពដីមានជីជាតិ ៥៥%

-ស្ថានភាពដីខ្សោះជីជាតិ ១០%

-ទៅលើប្រភេទដំណាំស្រូវមានការប្រើប្រាស់ពូជស្រូវក្នុងស្រុក និង ពូជកសិកម្មមកធ្វើការផ្សព្វផ្សាយ ដែលមានទិន្នផល ខ្ពស់ ជាប្រភេទស្រូវកណ្តាលដូចជា : ផ្ការំដួល, ខា១, ខា៩, ខា៤, ខា៥, ខា៦, ខា៣ ។

-ប្រភពទឹកសំរាប់ធ្វើការស្រោចស្រព គឺទទួលយកបានពីទំនប់ស្ទាក់ទឹកភ្លៀងបណ្តោះ ជាការជីកប្រឡាយ គឺដើម្បីនាំយកពីក្បាលទំនប់ស្ទាក់ទឹក ក្រៅពីនោះពុំមានអាងស្តុកទឹកសំរាប់ផ្តល់ការស្រោចស្រពរដូវរាំងស្ងួត និង រដូវប្រាំងនោះឡើយ ថ្វីត្បិតតែបឹង ត្រពាំងធំ អាចជាអាងស្តុកទឹកបាន តែគ្មានលទ្ធភាពយកមកប្រើប្រាស់បាន ។

-ទិន្នផលទាប ឬខ្ពស់ គឺអាស្រ័យអំណោយទឹកភ្លៀងគ្រប់គ្រាន់ ដែលជាការវាស់ស្ទង់ទិន្នផលគឺ :

-បើស្ថានភាពទឹកភ្លៀងពុំគ្រប់គ្រាន់ទិន្នផល

-បើស្ថានភាពទឹកភ្លៀងគ្រប់គ្រាន់ទិន្នផល

**+ឱកាសអាចជួយបានដល់ការផលិតផលស្បៀងបាននោះគឺ :**

-រកប្រភពធ្វើអាងទឹកស្រោចស្រព

-ជីក ស្តារត្រពាំង ប្រឡាយទឹក ម៉ាស៊ីនបូមទឹក ជាជំនួយ

-ជួយធ្វើការជំរុញអោយកសិករលើកប្រព័ន្ធភ្លឺស្រែ

-បិទទប់ជាទំនប់ស្ទាក់ទឹក តាមដងអូរ ឬស្នាមភ្លោះ

-ការផ្តល់ជូនពូជស្រូវដែលមានទិន្នផលខ្ពស់ ការផ្សព្វផ្សាយនូវបច្ចេកទេសកសិកម្មទំនើប និងប្រើប្រាស់ជីធម្មជាតិ ជូនប្រជាពលរដ្ឋឱ្យបានគ្រប់គ្រាន់ និងទូលំទូលាយ ។

+ **ឧបសគ្គ**

-ខ្វះថវិកា និងបច្ចេកទេសគាំទ្រដើម្បីធ្វើការស្តារឡើងវិញនូវធនធានក្នុងឃុំដែលមានស្រាប់ ។

-ភាពរាំងស្ងួត គឺធ្វើអោយផលដំណាំមានការលូតលាស់យឺតយ៉ាវ ទិន្នផលថយចុះ ។

-ការខ្វះខាតសំភារៈ សត្វគោ ក្របី ជាកម្លាំងអូសទាញ របស់ប្រជាពលរដ្ឋ ។

-ការផ្តល់ជូនពូជស្រូវដែលមានទិន្នផលខ្ពស់ ការផ្សព្វផ្សាយនូវបច្ចេកទេសកសិកម្មទំនើប និងប្រើប្រាស់ជីធម្មជាតិ ជូនប្រជាពលរដ្ឋ ពុំទាន់បានទូលំទូលាយទូទាំងឃុំនៅឡើយ ឱ្យ ប្រពលវប្បកម្ម............... ។

-ការបន្ទាក់ទុនដល់ប្រជាពលរដ្ឋនៅរដូវដកស្ទូង ធ្វើឡើងភាគច្រើនតាមលក្ខណៈឯកជនហើយមានការប្រាក់ខ្ពស់ ។

**តារាងទី១៣: ផលិតភាពដំណាំស្រូវ ក្នុងឃុំ**

| ប្រភេទដំណាំស្រូវ | ផ្ទៃដី (ហិកតា) | | ទិន្នផល | |
|---|---|---|---|---|
| | ផ្ទៃដីសរុប | អនុវត្តបាន | ទិន្នផលសរុប (តោន) | មធ្យមប្រចាំឆ្នាំ (តោត/ហ.ត) |
| **ស្រូវវស្សា** | | | | |
| ស្រូវវស្សាពឹងពាក់ទឹកភ្លៀង | ៤៧១២.១៤ | ២៣២០ | ៣៧១២ | ១.៦ |
| ស្រូវវស្សាបញ្ចូលទឹក | 0 | 0 | 0 | 0 |
| **ស្រូវប្រាំង** | | | | |
| ស្រូវប្រាំងប្រដេញទឹក | 0 | 0 | 0 | 0 |
| ស្រូវប្រាំងបញ្ចូលទឹកទាំងស្រុង | 0 | 0 | 0 | 0 |
| **ស្រូវចំការ** | | | | |
| ស្រូវចំការ | 0 | 0 | 0 | 0 |

ប្រភពទិន្នន័យ: មន្ទីរផែនការខេត្តសៀមរាប

**តារាងទី១៤: គ្រួសារទំហំដីស្រែតិច និង តំលៃស្រូវ**

| ផ្ទៃដីស្រែះ | ចំនួនគ្រួសារ |
|---|---|
| គ្រួសារដែលមានដី តិចជាង ១ហិកតា | ២៧០ |
| **ទិន្នផល** | **ឯកតា (តោន/ហិកតា)** |
| អតិបរិមា | ១,៤ |
| អប្បបរិមា | ០,៧ |
| **តំលៃស្រូវ** | **ឯកតា (រៀល/គីឡូក្រាម)** |
| ខ្ពស់បំផុត | ១០០០ |
| ទាបបំផុត | ៥៨០ |

ប្រភពទិន្នន័យ: មន្ទីរផែនការខេត្តសៀមរាប

### ១.៣.៣.២ ផលិតកម្មដំណាំរួមផ្សំ

ការធ្វើផលិតកម្មដំណាំរួមផ្សំ ក្រោយការច្រូតកាត់ប្រមូលផល ប្រជាជនចាប់ផ្តើមបន្តធ្វើការភ្ជួររាស់ដី ស្រែ ពួកគាត់ដែលមាននៅជិតប្រភពទឹក ដែលជាប្រភេទដំណាំងាយឆាប់ទទួលផល ក្នុងការបង្កើតនូវសេដ្ឋកិច្ច គ្រួសារ ពួកគាត់បាន មួយកំរិតបន្ថែមទៀត ។

ប្រភេទដំណាំដែលធ្វើការដាំដុះនៅរដូវប្រាំងនោះពុំមានទ្រង់ទ្រាយជាសហគមន៍ គឺការធ្វើជាលក្ខណៈ គ្រួសារ ភាគច្រើន ប្រៀបបានទៅនឹងតំបន់ដែលកំពុងមានការអភិវឌ្ឍន៍ ដូច្នេះដែរ គឺមូលដ្ឋានភូមិភូមិពង្រ ភូមិជំពូង ភូមិនគភាស១ ភូមិនគភាស២ ជាតំបន់មានប្រភេទ ស្រទាប់ខ្សាច់ច្រើន ។

ឱកាសជាច្រើនដែលអាចជួយដល់ពួកគេ ធ្វើការរៀបចំជាសហគមន៍គាំទ្រ បរិក្ខា សំភារៈ ហើយផលិតផលទាំងនេះ មានដំណើរទៅទីផ្សារល្អ ។

បើជាឧបសគ្គវិញនោះ ខ្វះប្រភពទឹក ខ្វះថវិកា សំរាប់ទ្រទ្រង់ធនធានដែលមានស្រាប់ ។

## តារាងទី១៥: ផលិតភាពដំណាំរួមផ្សំ

| ប្រភេទដំណាំ | ផ្ទៃដី (ហិកតា) | | ទិន្នផល | |
|---|---|---|---|---|
| | ផ្ទៃដីសរុប | អនុវត្តបាន | ទិន្នផលសរុប (តោន) | មធ្យមប្រចាំឆ្នាំ (តោត/ហ.ត) |
| ពោត | ២ | ២ | | ៣.៥០ |
| សណ្តែកសៀង | - | - | | - |
| សណ្តែកបាយ | ០.៥ | ០,៥ | | ០.៩០ |
| សណ្តែកដី | - | - | | - |
| ដំឡូមី | ២ | ២ | | ១២.៣០ |
| ដំឡូងជ្វា | - | - | | - |
| ល្ង | - | - | | - |
| | | | | |

ប្រភពទិន្នន័យ: មន្ទីរ កសិកម្មខេត្តសៀមរាប

## តារាងទី១៦: គ្រួសារទំហំដីចំការតិច និង ការប្រើប្រាស់ជីគីមី, ថ្នាំគីមី

| ដំណាំ ចំការ | ចំនួនគ្រួសារ |
|---|---|
| **ទំហំផ្ទៃដី** | |
| តិចជាង ១ហិកតា | ០ |
| ពុំមានដីស្រែផ្ទាល់ខ្លួន | ០ |
| **ការប្រើប្រាស់ ជីគីមី និង ថ្នាំគីមី** | |
| ការប្រើប្រាស់ជីគីមីចំពោះដំណាំ | ៩៨៥ |
| ការប្រើប្រាស់ថ្នាំគីមីចំពោះដំណាំ និង សត្វល្អិត | ៦៨៥ |

ប្រភពទិន្នន័យ: មន្ទីរផែនការខេត្តសៀមរាប

### ១.៣.៣.៣ ផលិតកម្មដំណាំឧស្សាហកម្ម

ការធ្វើផលិតកម្មដំណាំរួមផ្សំ ក្រោយការច្រូតកាត់ប្រមូលផល ប្រជាជនចាប់ផ្តើមបន្តធ្វើការភ្ជួររាស់ដី ស្រែ ពួកគាត់ដែលមាននៅជិតប្រភពទឹក ដែលជាប្រភេទដំណាំទាំងនោះងាយឆាប់ទទួលផល ក្នុងការបង្កើនទូវ សេដ្ឋកិច្ចគ្រួសារ ពួកគាត់បានមួយក៏រិតបន្ថែមទៀត ។

ប្រភេទដំណាំដែលធ្វើការដាំដុះក្នុងនារដូវប្រាំងនោះ ពុំមានទ្រង់ទ្រាយជាសហគមន៍ គឺការធ្វើការជា លក្ខណៈគ្រួសារភាគច្រើន ប្រៀបបានទៅនឹងតំបន់ដែលកំពុងមានការអភិវឌ្ឍន៏ដូច្នោះដែរ គឺនៅលើមូលដ្ឋានភូមិ ជំពូង, ពង្រ, នគរភាស១ នគរភាស២ ជាតំបន់មានប្រភេទស្រទាប់ដីខ្សាច់ច្រើន ។

-ឱកាសជាច្រើនដែលអាចជួយដល់ពួកគាត់ ដើម្បីធ្វើការរៀបចំជាសហគមន៏គាំទ្របរិក្ខាសំភារៈ ហើយផលិតផលទាំងនោះមានដំណើរនៅទីផ្សារល្អ ។

-បើជាឧបសគ្គវិញនោះខ្វះប្រភពទឹក ខ្វះថវិកា ស្ថានធនធានដែលមានស្រាប់ ។

## ១.៣.៤ ធនធានធម្មជាតិ

### ១.៣.៤.១ ធនធានព្រៃឈើ

ឃុំនគរភាសពុំសូវមានធនធានព្រៃឈើនៅសេសសល់នោះទេ គឺមានការបាត់បង់តាំងពីឆ្នាំ១៩៩០ មកម្ល៉េះ អ្វីដែលនៅ មាន សេសសល់តិចតួចជាប្រភេទព្រៃផ្សេងៗតែប៉ុណ្ណោះ ហើយជាដីមានជីជាតិមធ្យម ។

ជាឱកាសដែលអាចធ្វើឱ្យបានប្រសើរឡើងវិញនូវធនធានធម្មជាតិ គឺត្រូវមានផែនការដាំដុះឱ្យបានជាប្រ ចាំដូចជាទីទួលបុរាណ តាមដងផ្លូវសាធារណៈ តាមអាគារសាធារណៈផ្សេងៗ ឬតាមប្រព័ន្ធភ្លឺស្រែ (ដូចជាដើម សង្កែ) ។

ជាឧបសគ្គខ្វះជំនួយថវិកាដើម្បីធ្វើការបណ្តុះកូនឈើ និងផែនការហ៊ឹងម៉ាត់ដើម្បីការពារ ។

ដោយកំនើនប្រជាពលរដ្ឋ និងកត្តាសេដ្ឋកិច្ច ភាពរិចរិលនៃធម្មជាតិស្ទើរបាត់បង់ទាំងស្រុង គំរូវការពង្រីក ដីស្រែចំការ លំនៅដ្ឋាន និងទីតាំងអាគារសាធារណៈ ។ ទន្ទឹមនឹងនោះ គ្រោះធម្មជាតិមានការប្រែប្រួលអាកាស ធាតុខុសរដូវកាលបណ្តាលអោយការធ្វើវិស័យកសិកម្ម ដែលរង់ចាំទឹកភ្លៀងទទួលនូវភាពរាំងស្ងួតជាបន្តបន្ទាប់ ដោយមូលហេតុបាត់បង់ព្រៃឈើ ។

ការរកឱកាសកាប់កូនឈើ បោចវល្លិ ជាដើម គឺប្រជាពលរដ្ឋអាចរកក្នុងភូមិសាស្ត្រព្រៃនោះបាន ដោយមិនពិបាកទិញ ឬដូរពីក្រៅឃុំមកទេ ដូច្នេះការប្រើប្រាស់ផលអនុផលព្រៃឈើ ពុំអាចរកយកមកប្រើប្រាស់ពង្រីកមុខរបរ ធំដុំបានឡើយ ។

ជាឱកាស ដែលអាចធ្វើការ បានប្រសើឡើងវិញនោះ យើងបានរៀបចំអោយមានការការពារ ការដាំបន្ថែមតាមទីទួល តាមដងផ្លូវ តាមទីសាធារណៈផ្សេងៗ ឬតាមប្រព័ន្ធភ្លឺស្រែជាដើម ។

### ១.៣.៤.២ ធនធានជលផល

ប្រជាពលរដ្ឋក្នុងអាចនេសាទ នៅតាមអូរ បឹង ត្រពាំង ដែលមានទីតាំងចំងាយពី ៥០០ -១០០០ ម៉ែត្រពីភូមិ។ ការនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទធម្មតាតាមទំលាប់ និងមានប្រពៃណីទំនៀមទំលាប់នេសាទជាសហគមន៏រួមគ្នា ភូមិមួយ ឬពីរ នៅបឹង ឬត្រពាំងធំៗ ដើម្បីចាប់ត្រី រៀបចំធ្វើម្ហូបអាហារ ក្នុងពិធីបុណ្យប្រចាំភូមិរួម។ ប្រភេទត្រីបច្ចុប្បន្នមានដូចជា ត្រីរ៉ស ត្រីអណ្តែង ត្រីសណ្តាយ ត្រីឆ្លាំង ត្រីឆ្ពួញ ត្រីក្រាញ់ និង ត្រីកេះ ប៉ុន្តែ ប្រភេទត្រីទាំងនេះចេះតែថយចុះបន្តិចម្តងៗ ដោយសារកំនើតប្រជាជន និងការប្រើប្រាស់ឧបករណ៍ហាមឃាត់ ។នៅរដូវប្រាំង មានភាពរាំងស្ងួត បឹង ឬត្រពាំង មួយចំនួនបានរីងស្ងួត បណ្តាលឱ្យងាប់ត្រីពូជសំរាប់ឆ្នាំក្រោយៗទៀត រីឯការ ចិញ្ចឹមត្រីជា លក្ខណៈគ្រួសារ ជាសហគមន៍ និងជាលក្ខណៈក្រុមហ៊ុនពុំទាន់មាននៅឡើយទេក្នុងឃុំនេះ។ ផលត្រីដែលបានមក ពីការនេសាទគឺដើម្បីតែផ្គត់ផ្គង់តំរូវការក្នុងគ្រួសារប៉ុណ្ណោះ ពុំមានការនេសាទសំរាប់លក់ដូរជា
ទ្រង់ទ្រាយធំទេ។

ត្រពាំងមានអូរធំៗ នៅតាមភូមិមួយចំនួន ក្នុងឃុំដែលមានទំហំតូចបំផុត ៦០០០ម$^{២}$ សមល្មម និងចងក្រងជាសហគមន៏តែរកធនធានទាំងនោះមកធ្វើការចិញ្ចឹម ព្រោះបច្ចុប្បន្នប្រជាជនមានលទ្ធភាព ពួកគាត់ មានជីធ្លីបានធ្វើការជីកស្រះដែលមានទំហំ ១០ម x ១០ម សំរាប់បញ្ចូលត្រីក្នុងរដូវរំហើយ ដែលជាប្រភេទត្រី អណ្តែង ត្រីក្រាញ់ ដែលជាប្រភេទត្រីធម្មជាតិ ។

-ឱកាសទាំងនេះប្រជាពលរដ្ឋខ្វះខាតថវិកា និងខ្វះជំនួយបច្ចេកទេស

### ១.៣.៥ ធនធានរ៉ែ

នៅក្នុងឃុំ ពុំមានរ៉ែធម្មជាតិ និងប្រភេទធនធានធម្មជាតិផ្សេងៗទេ ឧ.បើសិនជាត្រូវការ សាង សង់សំណង់នានា ឬផ្លូវលំគ្រួសក្រហម នោះត្រូវដឹកជញ្ជូនពីខាងក្រៅស្រុក ដូចជា ថ្មអាចយកមកពី ឃុំគោកដូង ក្នុងស្រុកអង្គរជុំ និងគ្រួសក្រហមត្រូវដឹកចំងាយប្រហែល ២៤គីឡូម៉ែត្រ ពីឃុំស្វាយសរ ស្រុកវ៉ារិន និងខ្សាច់អាចយកពីឃុំដូនកែវស្រុកពួក ចំងាយ៣០ គីឡូម៉ែត្រ ពីឃុំនគភាស ។

## ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១ ទីផ្សារ និងតំលៃកសិផល ផលអនុផលព្រៃឈើ និង ផលនេសាទ

បើធ្វើការប្រៀបធៀបដោយ តំលៃផលិផលកសិកម្ម ឧ.ដូចជា ផលិតផល ពីដំណាំរួមផ្សំ ផលនេសាទ នៅលើទីផ្សារទទួលបានតំលៃស្តួចស្តើង ជាពិសេសសំរាប់តម្រូវការក្នុងគ្រួសារទេប៉ុណ្ណោះ ។ ប៉ុន្តែផលិតផល ស្រូវមានតម្លៃសមរម្យតាមទីផ្សារក្នុងស្រុក ដែលធ្វើអោយអ្នកផលិតទទួលយកបាន ដោយមានឈ្មួញចុះទិញដល់ផ្ទះកសិករ

តែម្តង រីឯតំលៃអនុផលព្រៃឈើវិញ ពុំទាន់បានទាញយកផលធំដុំនៅឡើយ ។

បើយើងធ្វើការគិតអំពីចរាចរផលិតផល ទៅនិងចំងាយផ្លូវនៃការដឹកជញ្ជូនមករកទីផ្សារ ផលចំណេញ គឺបាន តិចតួចណាស់ ព្រោះយើងគ្មានផលិតផលធំដុំសំរាប់នាំចេញក្រៅស្រុកបានឡើយ ។

ជាឱកាសល្អលើប្រភេទកសិផលស្រូវ ដែលយើងអោយកសិករមានទឹកចិត្តក្នុងការផលិត ពុំមានការ កកស្ទះឡើយ ក្នុងការធ្វើចរាចរទៅទីផ្សារ ។

ការធ្វើចរាចរផលិតផល ឬទេសាទនោះ គឺមានចលនាល្អណាស់ក្នុងការលក់ទៅឱ្យទីផ្សារ ដោយ មានការទិញដល់ទីកន្លែង និងមានកន្លែងសំរាប់ដាក់លក់ជាប្រចាំពីព្រឹករហូតដល់ល្ងាច ។

## ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

ឃុំពុំមានផ្សារក្នុងឃុំទេ ប៉ុន្តែឃុំអាចប្រើប្រាស់ផ្លូវគ្រួសក្រហមមួយខ្សែ ដឹកជញ្ជូនផលិតផលកសិកម្ម ដើម្បីធ្វើការដោះដូរទំនិញ នៅផ្សារទីរួមខេត្តសៀមរាប ដែលមានចំងាយផ្លូវប្រហែល ៥0 គីឡូម៉ែត្រ ។

ផលិតផលកសិកម្មខ្លះត្រូវបាននាំចេញទៅក្រៅស្រុក និងក៏មានការនាំចូលផលិតផលមកក្នុងស្រុកវិញផងដែរ ។

**<u>ឱកាសនិង ឧបសគ្គ</u>**

ផលស្រូវដែលកសិករ ផលិតបានពុំមានសេសសល់និងកកស្ទះឡើយ ក្នុងការធ្វើចរាចរនៅលើទីផ្សារ ។ កត្តាជាឧបសគ្គចំពោះដំណាំកសិឧស្សាហកម្មមានលទ្ធភាពអាចដាំដុះបាន តែពុំទាន់មានធនធាន និងការវិនិយោគនៅឡើយ ។

# ជំពូក២

# ការវិភាគពីសក្តានុពល ឧបសគ្គ និងតំរូវការសំរាប់អនាគត

## ២.១ ចំណោលប្រជារាស្ត្រគិតដល់ឆ្នាំ ២០២២

### ២.១.១ អត្រាកំណើន

អត្រាកំណើនប្រជាជនពីចន្លោះឆ្នាំ២០០៥ ដល់ ឆ្នាំ២០០៨ មានការកើនឡើងខ្លាំង ដោយគិតជាមធ្យម ១,៧៥% ប្រចាំឆ្នាំ ស្មើនឹង ១៤៩ នាក់/១ឆ្នាំ។ បំរែបំរួលចំនួនប្រជាជនមានការកើនឡើង នៅក្នុងឆ្នាំ ២០០៥ ដល់ ឆ្នាំ២០០៨ នេះដោយហេតុតែ មានការបំបែកគ្រួសារថ្មី ដែលទើបរៀបអាពាហ៍ពិពាហ៍រួច និង ម្យ៉ាងទៀតតំបន់នេះ នៅដាច់ស្រយ៉ាល ដែលសេវាកម្មផ្សព្វផ្សាយអំពីការពន្យាកំណើត ពិបាកចូលទៅដល់តំបន់រស់នៅរបស់ប្រជាជន។ កំណើនប្រជាជនកើនឡើងនាំអោយមានកើនឡើងនូវលំដ្ឋានថ្មីៗ , តំរូវការដីកសិកម្មដើម្បីបង្កបង្កើនផល ព្រោះមុខរបរប្រជាជនតំបន់នេះ គឺអាស្រ័យលើការងារធ្វើស្រែជាចំបង។

**តារាងទី១៧: ស្ថិតិប្រជាជនតាមឆ្នាំ**

| ឆ្នាំ | ចំនួនប្រជាជនតាមឆ្នាំ គិតជា នាក់ | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រជាជន | អត្រាកើត | អត្រាស្លាប់ | ការហូរចូល | ការហូរចេញ | ផ្លាស់ប្តូរ | អត្រា |
| ២០០៥ | ៨១០៧ | | | | | | |
| ២០០៦ | ៨១១៧ | | | | | | |
| ២០០៧ | ៨១២៦ | | | | | | |
| ២០០៨ | ៨៥៣៤ | | | | | | |

ប្រភពទិន្នន័យ: ស្ថិតិឃុំ

### ២.១.២ ចំណោលប្រជាសាស្ត្រ

យោលតាមទិន្នន័យស្ថិតិប្រជាជននៅក្នុងឃុំ តាមបណ្តាឆ្នាំកន្លងមកនេះ ក្រុមប្រឹក្សាឃុំអាចធ្វើការគណនាចំណោលប្រជាសាស្ត្រលើចំនួនប្រជាជន ស្រី ប្រុស និង ក្រុមមនុស្សតាមអាយុ សំរាប់រៀបចំផែនការឆ្លើយតបតាមតំរូវការរបស់ប្រជាជនក្នុងឃុំ នៅឆ្នាំ២០២២នាពេលអនាគត បានល្អប្រសើ។

ដោយអត្រាកំនើនមធ្យមប្រចាំឆ្នាំ: ១,៧៥ % ( ការប្រៀបធៀបចំនួនប្រជាជនខុសៗគ្នារវាងឆ្នាំ២០០៥-២០០៨) ដូចនេះប្រជាជនកើនឡើងនៅក្នុងឆ្នាំ២០២២ត្រូវបានគណនាដូចខាងក្រោម:

⇒ចំនួនមនុស្សកំនើនមធ្យមប្រចាំឆ្នាំ :១,៧៥% x ៨ ៥៣៤នាក់ = ១៤៩ នាក់/១ឆ្នាំ

⇒ ចំនួនកំនើនប្រជាជនក្នុងរយ:ពេល ១៣ឆ្នាំ : ១៤៩នាក់ x ១៣ : ១៩៤៣នាក់

⇒ ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០២២ : ១៩៤៣នាក់ + ៨៥៣៤ នាក់ :១០ ៤៧៧នាក់

ដូច្នេះប្រជាជនសរុបក្នុងឆ្នាំ២០២២ មាន : ១០ ៤៧៧នាក់

និងកំណើនគ្រួសារសរុប : ១ ៨៣៨គ្រួសារ ។

**តារាងទី១៨: កំនើតប្រជាជនតាមអាយុ និង បំរែបំរួលកំនើនប្រជាជន ឆ្នាំ២០២២**

| អាយុ | ប្រជាជនក្នុង ឆ្នាំ២០០៨ (នាក់) | ប្រជាជន ក្នុងឆ្នាំ២០២២ (នាក់) | បំរែបំរួលកំនើនប្រជាជន (នាក់) |
|---|---|---|---|
| ក្រោម ២ ឆ្នាំ | ៥៨៧ | ៧២១ | ១៣៤ |
| ៣-៤ ឆ្នាំ | ៤៣៣ | ៥៣២ | ៩៩ |
| ៥ ឆ្នាំ | ៣៥៥ | ៤៣៦ | ៨១ |
| ៦ ឆ្នាំ | ៣៣៧ | ៤១៤ | ៧៧ |
| ៧-១១ ឆ្នាំ | ៩៤៥ | ១១៦០ | ២១៥ |
| ១២-១៤ ឆ្នាំ | ៧២៧ | ៨៩៣ | ១៦៦ |
| ១៥-១៧ ឆ្នាំ | ៧៣៩ | ៩០៧ | ១៦៨ |
| ១៨-២៤ ឆ្នាំ | ១០៩៥ | ១៣៤៤ | ២៤៩ |
| ២៥-៣៥ ឆ្នាំ | ១២៣៧ | ១៥១៩ | ២៨២ |
| ៣៦-៤៥ ឆ្នាំ | ១០២០ | ១២៥២ | ២៣២ |
| ៤៦-៦០ ឆ្នាំ | ៧៤២ | ៩១១ | ១៦៩ |
| ៦១ ឆ្នាំ ឡើង | ៣១៧ | ៣៨៩ | ៧២ |
| **ប្រជាជនសរុប(នាក់)** | ៨៥៣៤ | ១០៤៧៧ | ១៩៤៣ |

ប្រភពទិន្នន័យ:សៀវភៅស្ថិតិឃុំ

កំណើនប្រជាជននៅឆ្នាំ២០២២ នឹងកើនដល់ ១០ ៤៧៧នាក់ គឺស្មើនឹងចំនួន ១ ៩៤៣នាក់ បន្ថែមលើចំនួនប្រជាជន ដែលមានក្នុងពេលបច្ចុប្បន្ននេះ ។ បើពិនិត្យទៅក្រុមអាយុរបស់កុមារ ពី៦ ដល់ ១១ឆ្នាំ មានការកើនឡើងចំនួន ១ ៥៧៤នាក់(ចំនួនសរុប)នេះមានន័យថានៅឆ្នាំ២០២២ នឹងមានតំរូវការកើនឡើង នូវការសាងសង់សាលាបឋមសិក្សាបន្ថែម ទៀត ដើម្បីឆ្លើយតបទៅ តំរូវការកុមារដែលមានអាយុគ្រប់ចូលរៀនសាលាបឋមសិក្សា ។

ពីមួយឆ្នាំទៅមួយឆ្នាំ កុមារដែលរៀនចប់ បឋមសិក្សា ត្រូវបន្តអនុវិទ្យាល័យ និង វិទ្យាល័យ ចេះតែកើនឡើងៗ ជាលំដាប់ ហើយបើពិនិត្យមើលក្រុមមនុស្សដែលមានអាយុចាប់ពី១២ឆ្នាំ ដល់ ១៧ឆ្នាំ នៅឆ្នាំ២០២២ មានការកើនឡើង ដល់ ១ ៨០០នាក់(ចំនួនសរុប) ។ ដូច្នេះសាលារៀនអនុវិទ្យាល័យ និង វិទ្យាល័យត្រូវតែសាងសង់បន្ថែមផងដែរ ។

## ដ្យាក្រាមទី៦: ប្រៀបធៀបកំណើតប្រជាជនតាមអាយុ ក្នុងឆ្នាំ២០០៨ និងអនាគតឆ្នាំ២០២២




ប្រភពទិន្នន័យ:សៀវភៅស្ថិតិឃុំ

## ២.២ តម្រូវការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំ

ការងារអភិវឌ្ឍន៍ និងគំរោងអភិវឌ្ឍន៍ឃុំចាំបាច់ត្រូវឱ្យសមស្របទៅនឹងការប្រើប្រាស់ដីនៅក្នុងឃុំ កត្តាសក្តានុពលនៃដីដែលមានក្នុងឃុំ ក្នុងគោលបំណងអភិវឌ្ឍន៍ឱ្យមានចីរភាព ឧ. ដូចជាផែនការអភិវឌ្ឍន៍ឃុំរយៈពេល ០៥ ឆ្នាំ វិកិល និងកម្មវិធីវិនិយោគឃុំ ត្រូវបានធ្វើការប្រឹក្សាបានច្បាស់លាស់ពីក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋក្នុងឃុំ ពីបញ្ហា ដំណោះស្រាយ តំរូវការចាំបាច់របស់ប្រជាពលរដ្ឋ និងលទ្ធផលដែលរំពឹងទុក ។

សំរាប់ផែនការប្រើប្រាស់ដីនៅក្នុងឃុំអនាគត មានរយៈ ពេលពី ០៥ ទៅ ១៥ឆ្នាំ ដោយលើកគោលដៅអភិវឌ្ឍន៍នានាដែលអាចសំរេចបានជោគជ័យ និងទទួលលទ្ធផលតាមការរំពឹងទុក ។ ការធ្វើផែនការនេះ បានពិភាក្សាយ៉ាងហ្មត់ចត់ពីក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋក្នុងឃុំ និងស្ថាប័នពាក់ព័ន្ធនានា ដោយមានអ្នកសំរបសំរួលពីក្រុមការងារ ក្តប ស្រុក និង ខេត្ត ។

## តារាងទី១៩: ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជំរើសនៃការប្រើប្រាស់ដីធ្លីអនាគត

| កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀងនៅលើផែនទី |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១. ទិន្នផលកសិកម្មកើនឡើង<br><br>១.បង្កើនផលិតកម្មសត្វ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ៥ឆ្នាំ ២០០៨-២០១២ | ១.ធ្វើអោយប្រសើរឡើងនូវការធានាស្បៀងហូបគ្រប់គ្រាន់របស់ប្រជាពលរដ្ឋតាមមធ្យោបាយផលិតផលមុខរបរ ផលិតកម្ម | ១.បង្កើនទិន្នផលស្រូវពី១តោនទៅ៣តោនក្នុង១ហិតា<br><br>១.បង្កើនប្រាក់ចំណូល | -ជីកប្រឡាយ<br>-ជីកស្រះក្នុងស្រែ<br>-ស្តារប្រឡាយ<br>-បច្ចេកទេសដាំស្រូវ<br>-បច្ចេកទេសធ្វើជីកំប៉ុស្តិ៍<br>-បច្ចេកទេសធ្វើថ្នាក់ចាត់សត្វល្អិត<br>-បច្ចេកទេសដាំដំណាំ<br>-ផ្តល់ពូជស្រូវទិន្នផលខ្ពស់<br>-ផ្តល់ពូជបន្លែគ្រប់មុខ<br>-ធ្វើទ្វារទឹកខ្នាតធំ<br>-ជំរុញក្រុមគ្រប់គ្រងធានាគារស្រូវ<br>-បង្កើតឥណទានសាច់ប្រាក់<br>-បង្កើនធនាគារគោ<br>-បណ្តុះបណ្តាលពេទ្យសត្វភូមិ<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ<br>-ចាក់វ៉ាក់សាំងការពារជំងឺសត្វ<br>-ផ្តល់ពូជជ្រូកល្អ<br>- ផ្តល់ពូជមាន់ល្អ<br>- ផ្តលពូជមាន់ល្អ<br>-ផ្តល់ពូជត្រីល្អ | |
| ២. ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ល្អប្រសើ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ៥ឆ្នាំ ២០០៨-២០១២ | ២.ធ្វើអោយប្រសើរឡើងរបស់ប្រជាពលរដ្ឋក្នុងឃុំមានផ្លូវធ្វើដំណើរស្រួលជាងមុន | ២.កែលំអរផ្លូវក្នុងឃុំអោយបានល្អប្រសើរ | -ផ្លូវក្រាលគ្រួសក្រហម<br>- ជួសជុលផ្លូវដីស<br>-សង់លូកាត់ផ្លូវ | |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| ៣. ការសិក្សាកុមារបានគ្រប់គ្នា និងសាលារៀនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍឃុំ ៥ឆ្នាំ ២០០៨-២០១២ | ៣.ធ្វើអោយប្រសើរឡើងរបស់កុមារាកុមារីបានចូលរៀន និង មានចំណេះដឹងគ្រប់ៗគ្នា និងបង្កើនការអប់រំឪពុកម្តាយ | ៣. បង្កើន និង កែលំអរសេវាអប់រំកុមារ | -ផ្សព្វផ្សាយអំពីសិទ្ធិកុមារ<br>-បើកវគ្គបណ្តុះបណ្តាលដល់ឪពុកម្តាយ<br>-ផ្តល់អាហាររូបករណ៍<br>-សាងសង់សាលារៀន | |
| ៤. ការសិក្សាប្រជាពលរដ្ឋបានគ្រប់គ្នា | សៀវភៅផែនការអភិវឌ្ឍឃុំ ៥ឆ្នាំ ២០០៨-២០១២ | ៤.បង្កើនការអប់រំក្រៅប្រព័ន្ធអោយបានល្អ | ៤. បង្កើនចំណេះដឹងប្រជាពលរដ្ឋអោយល្អប្រសើរ | -បើកថ្នាក់អក្ខរកម្ម<br>-សុំថវិការឧបត្ថម្ភដល់គ្រូអក្ខរកម្ម | |
| ៥. សុខភាពរបស់ប្រជាជន ល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍឃុំ ៥ឆ្នាំ ២០០៨-២០១២ | ៥. ការផ្តល់សេវាសុខភាព បង្កើនចំណេះដឹងដល់ភ្នាក់ងារអ្នកទ្រទ្រង់ភូមិ | ៥.បង្កើន និង កែលំអរសេវាសុខភាព | -ចាក់វ៉ាកសាំងការពារជំងឺ ៧មុខ<br>-បណ្តុះបណ្តាលឆ្មបបុរាណ<br>-អប់រំអំពីការថែទាំសុខភាព<br>-កម្មវិធីពន្យាកំនើត,<br>-ផ្តល់អាហារូបត្ថម្ភ<br>-សង់បង្គន់អនាម័យ<br>-ជំរុញការផ្តល់សេវាអោយទូលំទូលាយ<br>-កាត់បន្ថយមរណៈភាពមាតា និង ទារក<br>-ផ្តល់សេវាសុខភាព<br>-ផ្សព្វផ្សាយអំពីជំងឺអេដស៏<br>-អប់រំអំពីការបោសសំអាតភូមិ | |
| ៦.មានទឹកស្អាតសំរាប់ គ្រួសារប្រើប្រាស់ | សៀវភៅផែនការអភិវឌ្ឍឃុំ ៥ឆ្នាំ ២០០៨-២០១២ | ៦.ការរស់នៅមានអនាម័យល្អតាមមធ្យោបាយមានទឹកប្រើប្រាស់គ្រប់គ្រាន់ | ពង្រីក និង កែលំអប្រភពផ្គត់ផ្គង់ទឹកស្អាត | -ជីកអណ្តូងលូ, ស្នប់<br>-ជីកស្រះសហគមន៏,<br>-ផ្តល់ធុងចំរោះទឹកស្អាត | |
| ៧. | សៀវភៅផែនការអភិវឌ្ឍឃុំ ៥ឆ្នាំ ២០០៨-២០១២ | ៧.វប្បធម៌ប្រពៃណីខ្មែរ និង មានការរីកចំរើនប្រសើរឡើង | លើកកំពស់វិស័យវប្បធម៌អោយបានស្អាតស្អំឡើង | -បណ្តុះបណ្តាលវង់ភ្លេងបុរាណឡើងវិញ<br>-សាងសង់សាលាឆទាន | |

| | | | | | |
|---|---|---|---|---|---|
| | | | វិញ | | |
| ៨.ជីវភាពប្រជាជនល្អប្រសើជាងមុន | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ៥ឆ្នាំ ២០០៨-២០១២ | ៨.ធ្វើអោយប្រសើឡើងរបស់ប្រជាពលរដ្ឋក្នុងការរកចំណូលតាមមធ្យោបាយមានជំនាញផ្សេងៗ | បង្កើនចំណេះដឹងប្រជាពលរដ្ឋអំពីវិជ្ជាជីវៈ នានា | -បើកវគ្គបណ្តុះបណ្តាលកាត់ដេរ<br>-បណ្តុះបណ្តាលសិប្បកម្មតម្បាញ<br>-ជួសជុលគ្រឿងម៉ាស៊ីនម៉ាញ៉េ ទូរទស្សន៍ | |
| ៩.ឃុំមានធនធានធម្មជាតិ និង បរិស្ថាន ល្អ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ៥ឆ្នាំ ២០០៨-២០១២ | ៩.ប្រជាពលរដ្ឋមានការយល់ដឹងអំពីអត្ថប្រយោជន៍នៃការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន | ជំរុញការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន | - ដាំកូនឈើឡើងវិញ<br>-ផ្តល់ពូជកូនឈើ<br>-បង្កើតចង្រ្កានសន្សំអុស<br>- ផ្សព្វផ្សាយច្បាប់ការពារព្រៃឈើ | |
| ១០.ជីវភាពប្រជាជនល្អប្រសើរជាងមុន | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ៥ឆ្នាំ ២០០៨-២០១២ | ១០.ប្រជាពលរដ្ឋក្នុងឃុំរស់នៅប្រកបដោយសន្តិភាព និង សុវត្ថិភាពល្អដែលបង្កលក្ខណៈងាយស្រួលដោយប្រជាពលរដ្ឋក្នុងឃុំទទួលបានពិតមាននានា និង ការប្រកបចិញ្ចឹមជីវិត | -ផ្តល់សេវាកម្មប្រជាពលរដ្ឋអោយ បានល្អ<br>-ធានាទូវការផ្សព្វផ្សាយពិតមាននានាទាក់ទងនឹងការអភិវឌ្ឍន៍ក្នុងឃុំ | -អប់រំផ្សព្វផ្សាយអំពីច្បាប់ទំនាស់ផ្សេងៗ<br>-អប់រំអំពីថែទាំទ្រព្យសម្បត្តិ<br>- ផ្សព្វផ្សាយអំពីច្បាប់ដល់យុវវ័យ<br>- ផ្សព្វផ្សាយអំពីច្បាប់ចរាចរណ៍<br>- បង្កើនមុខរបរក្នុងស្រុកជូន ប្រជាពលរដ្ឋ | |
| ១១.សមភាព និង សមធិមក្នុងការរស់នៅ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ៥ឆ្នាំ ២០០៨-២០១២ | ១១.ប្រជាពលរដ្ឋនៅក្នុងឃុំចូលរួមយ៉ាងសកម្មក្នុងការលើកស្ទួយយេនឌ័រក្នុងឃុំ | -ផ្តល់ឱកាសអោយស្រ្តីបានចូលរួមក្នុងកិច្ចការសង្គមនានា<br>-បង្កើនចំណេះដឹងអំពីយេនឌ័រ | -អប់រំផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស<br>-បណ្តុះបណ្តាលយេនឌ័រ | |

ប្រភពទិន្នន័យ: សៀវភៅផែនការអភិវឌ្ឍន៍ឃុំ

## ២.៣ តម្រូវការសំរាប់អនាគត

ប្រជារាស្ត្រក្នុងឆ្នាំ ២០២២ តំរូវការដីធ្លីជាកត្តាចាំបាច់ទៅលើសំណង់លំនៅស្ថាន ដីសំរាប់ ផលិតផលកសិកម្ម ដើម្បីផ្គត់ផ្គង់សេដ្ឋកិច្ចសង្គមគ្រួសារ ដូច្នេះត្រូវដោះស្រាយយ៉ាងណាកំអោយប៉ះពាល់ធនធានធម្មជាតិ រឺគ្រោង តំបន់ណាមួយជាព្រៃរិចរិល រឺការបង្កើនគុណភាពដី និងសំរាប់ អាត្រាកំណើនឈានចូលដល់ដំណាក់កាលចាំបាច់ ។

### ២.៣.១ ដីលំនៅដ្ឋាន

ជាករណីចាំបាច់ក្នុងការរីកសាយគ្រួសារ តែក៏ត្រូវគិតថាផែនការជាការកំណត់ផ្ទៃដីដោយ មិនអោយធំពេក រឺតូចពេក សមល្មម និងទទួលយកបានដោយគិតអំពី បរិស្ថានសំណង់ និងសោភ័ណ្ឌភាពជុំវិញ ។តាមសមាមាត្រធៀបគ្រួសារបច្ចុប្បន្ន និង ផ្ទៃដីលំនៅដែលមាន គឺ មួយគ្រួសារជាមធ្យមទទួលបានដីលំនៅដ្ឋាន ០,២៥ហិកតា ដែលជាចំនួនមួយសមស្របសំរាប់តាំងទីលំនៅដ្ឋាន (អនុក្រិត្យស្តីពីដីសម្បទានសង្គមកិច្ច លេខ ១៩ អនក្រ. អបក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ជំពូកទី៥ មាត្រាទី១៦ ដីលំនៅដ្ឋានពី១២០០-៣៦០០ម៉ែត្រការេ) ។ ដូច្នេះតម្រូវការ លំនៅដ្ឋានបន្ថែមសំរាប់ឆ្នាំ២០២២ គឺ ៨៩ ហិកតា ។

**តារាងទី២០: តម្រូវការដីសំរាប់លំនៅដ្ឋាន ឆ្នាំ២០២២**

| | ២០០៨ បច្ចុប្បន្ន | អនាគត ២០២២ | បំរែបំរួលតម្រូវការ |
|---|---|---|---|
| គ្រួសារ | ១ ៤៨៣ | ១ ៨៣៨ | ៣៥៥ |
| តំរូវការដីលំនៅដ្ឋាន ពេលអនាគត ២០២២ (ហិកតា) | | | ៨៩ |

ប្រភពទិន្នន័យ: ការគណនាតាមតំរូវការចំណោលប្រជាសាស្ត្រ

### ២.៣.២ ដីកសិកម្ម

ដីកសិកម្មគឺរួមមានដីសំរាប់ ស្រែវស្សា និងចំការដំណាំ ។ តាមសមាមាត្រធៀបគ្រួសារ បច្ចុប្បន្នប្រកបរបរកសិកម្មជាចំបង ៩៤,៨៨ % និង យោង អនុក្រិត្យស្តីពីដីសម្បទានសង្គមកិច្ច លេខ ១៩ អនក្រ. អបក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ជំពូកទី៦ មាត្រាទី១៧ ដីកសិកម្ម ២ហិកតា ក្នុង ១គ្រួសារ ។ដូច្នេះតំរូវការដីកសិកម្ម ដែលរួមមានដំណាំស្រូវ និង ដំណាំចំការរួមផ្សំ ។

**តារាងទី២១: តម្រូវការដីសំរាប់កសិកម្ម ឆ្នាំ២០២២**

| | ២០០៨ បច្ចុប្បន្ន | អនាគត ២០២២ | បំរែបំរួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ ប្រកបរបរ កសិកម្មចំបង | ១៤០៧ | ១៧៤៦ | ៣៣៩ |
| តំរូវការដីកសិកម្មអនាគត (ហិកតា) | | | ៦៧៨ |

ប្រភពទិន្នន័យ: ការគណនាតាមតំរូវការចំណោលប្រជាសាស្ត្រ

**ចំពោះដំណាំស្រូវ**

សំរាប់គ្រួសារមួយគិតជាមធ្យម ៥ នាក់ ដូច្នេះតំរូវការស្បៀងហូបចុកក្នុងមួយឆ្នាំ ១២០០ គីឡូក្រាម។ ទិន្នផលស្រូវជាមធ្យម ១៣០០ គីឡូក្រាម/ហិកតា (ទិន្នន័យផែនការឃុំ) ដូច្នេះក្នុងមួយគ្រួសារត្រូវមានដីស្រែចំនួន ០,៩២ហិកតា។ នៅឆ្នាំ២០២២ ចំនួនគ្រួសារធ្វើស្រូវជាចំបងកើនដល់ ១៧៤៦គ្រួសារ(៩៤,៨៨%នៃគ្រួសារសរុប) ដោយកើនចំនួន ៣៣៩គ្រួសារថែមទៀត និង បូករួមគ្រួសារគ្មានដីស្រែ ៣១គ្រួសារ និង គ្រួសារមានដីស្រែតិចជា ១ហិកតាចំនួន ២៧០គ្រួសារ ដូចនេះ ដីស្រែត្រូវការ ៤៧៥,៤០ ហិកតាបន្ថែមទៀត។

តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

| | | | | |
|---|---|---|---|---|
| - ចំនួនគ្រួសារមានដីតិចជាង ១ហិកតា | ២៧០គ្រួ. | x ០,៥ | = | ១៣៥ ហត. |
| - កំណើនគ្រួសារ ២០២០ បន្ថែម | ៣៣៩គ្រួ. | x ០,៩២ | = | ៣១១,៨៨ ហត. |
| | សរុប | | | ៤៤៦,៨៨**ហត.** |

## ២.៣.៣ ដីព្រៃឈើ

ការចងក្រងសហគមន៍ព្រៃឈើ ដោយការទទួលស្គាល់ជាផ្លូវច្បាប់ ក្នុងវង្វង់សមត្ថកិច្ចការពារគ្រប់គ្រង ច្បាស់លាស់ កំណត់ដីព្រៃជាសម្បត្តិរដ្ឋដែលត្រូវការចាំបាច់ ការគាំទ្រចូលរួមពីអ្នកភូមិ ដោយ ពេញចិត្តនោះ សម្បត្តិព្រៃឈើ អាចកើតមានបរិស្ថានធម្មជាតិល្អបរិសុទ្ធ ។

ការទាញយកអនុផលព្រៃឈើ គឺថវិកាចំណូលរបស់សហគមន៍ដោយដកយកផលទាំងនោះ ទៅតាមបទដ្ឋានបច្ចេកទេស និងតម្រូវការចាំបាច់របស់សមាជិកសហគមន៍ក្នុងការប្រើប្រាស់ផ្សេងៗ ។ តម្រូវការឈើចាំបាច់សំរាប់បំរើថាមពលអុស ធ្យូង ជាប្រភេទឈើក្រៅលំដាប់ថ្នាក់ ដែលជា ករណីចាំបាច់អ្នកភូមិ ។

ផលចំណូលពីផល អនុផលព្រៃឈើ គឺអាចជួយរំលែកដល់ជនក្រីក្រគ្មានទីពឹង ឬក៏ការជួយ ឧបត្ថម្ភចំពោះសមាជិកដែលមានធុរៈ ។

## ២.៣.៤ ធនធានទឹក

ទំនប់ អាង ប្រព័ន្ធស្រោចស្រព គឺជាកត្តាចាំបាច់សំរាប់ការផលិតកម្ម កសិកម្ម ជួយទ្រទ្រង់នៅ ក្នុងដំណាក់កាលរាំងស្ងួត និងផ្តល់ភាពងាយស្រួលក្នុងការជួយអន្តរាគមន៍បានមួយផ្នែកផងដែរ (មានបង្ហាញរួមក្នុងតារាងផ្នែកបន្ទាប់)។

## ២.៣.៥ ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

ឃុំមានហេដ្ឋារចនាសម្ព័ន្ធសំរាប់បំពេញតាមតម្រូវការ មានគមនាគមន៏ ទាក់ទងទៅ មូលដ្ឋានភូមិ ឃុំ ជួយពន្លឿនក្នុងការធ្វើចរាចរទំនាក់ទំនងសាធារណៈការ ការដឹកជញ្ជូនផលិតផល ការជួយគាំទ្រការងារ សង្គម ជាពិសេស បំរើនៅសតិអារម្មណ៏ឱ្យប្រជាជន រីករាយ និងសកម្មភាពរស់រវើក ប្រៀបបាននិងសរសៃឈាមធ្វើចលនា មិននឿយហត់ ឡើយ ។

### តារាងទី២២: ផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មនានា

| ផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធ | | | |
|---|---|---|---|
| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំនេះ (គ.ម) | ប្រវែងផ្លូវ១៥ឆ្នាំ (គ.ម) | បំរែបំរួល (គ.ម) |
| ផ្លូវក្រាលកៅស៊ូ | 0 | ៨.១ | ៨.១ |
| ផ្លូវក្រាលគ្រួសក្រហម | ៦,0៥ | ២៥,៣៥ | ១៩.៣ |
| ផ្លូវលំដីស | ៣៧,0៨ | ៤១,0៨ | ៤ |
| ផ្លូវរទេះ/ថ្មើរជើង | ៧១,៣៧ | ៧១,៣៧ | ៧១,៣៧ |
| តំបន់/ប្រឡាយមេ | 0,៨៨ | ១២,២៨ | ១១.៤ |
| តំបន់/ប្រឡាយរង | ១២,៨៨ | - | ១២,៨៨ |
| ប្រវែង/ចំនួន លូ | ៦២ | ៧២ | ១0 |
| ប្រវែង/ចំនួន ស្ពាន | ១ កន្លែង | ៣ កន្លែង | ២ កន្លែង |
| ប្រវែង/ចំនួន សំណង់បង្ហូរ | - | ១ កន្លែង | ១ កន្លែង |
| **ផែនការផ្នែកសេវាកម្ម** | | | |
| **ប្រភេទសេវាកម្ម** | **ចំនួនក្នុងឆ្នាំនេះ** | **ចំនួន១៥ឆ្នាំក្រោយ** | **បំរែបំរួល** |
| សាលាមត្តេយ្យ | ៤ | 0 | ៤ |
| សាលាបឋមសិក្សា | ៧ | ១១ | ៤ |
| សាលាមធ្យមសិក្សា | ១ | ២ | ១ |
| ប៉ុស្តិ៍ សុខភាព | - | ១ | ១ |
| មណ្ឌលសុខភាព | ១ | - | ១ |
| ទីតាំងផ្សារឃុំ | 0 | ១ | ១ |
| កន្លែងចាក់សំរាម | 0 | 0 | 0 |
| សាលាឆទាន | 0 | 0 | 0 |
| វត្ត | ១ | 0 | 0 |

ប្រភពទិន្នន័យ: ផែនការតំរូវការរបស់ឃុំ

**តារាងទី២៣: កំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០២២**

| ប្រភេទ សាលារៀន | អាយុ | សរុបប្រជា ជនក្នុង ឆ្នាំ២០២២ តាមអាយុ (នាក់) | តំរូវការសាលារៀន ឆ្នាំ២០២២ | | | សាលារៀន បច្ចុប្បន្ន | | | តំរូវការសាលារៀនបន្ថែម | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនខ្នង | ចំនួនបន្ទប់ | ចំនួនថ្នាក់ | ចំនួនខ្នង | ចំនួនបន្ទប់ | ចំនួនថ្នាក់ | ចំនួនខ្នង | ចំនួនបន្ទប់ | ចំនួនថ្នាក់ |
| មត្តេយសិក្សា | ៣-៥ឆ្នាំ | ៩៦៨ | ៤ | | | ៤ | ៤ | ៤ | ០ | ០ | ០ |
| បឋមសិក្សា | ៦ -១១ ឆ្នាំ | ១៥៧៤ | ៧ | ៣៥ | ៣៥ | ៧ | ២៨ | ៣៦ | ១ | ៧ | ៧ |
| ថ្នាក់អនុវិទ្យាល័យ | ១២-១៤ ឆ្នាំ | ៨៩៣ | ២ | ២០ | ២០ | ១ | ២ | ៣ | ១ | ១៨ | ១៨ |
| ថ្នាក់វិទ្យាល័យ | ១៥-១៧ ឆ្នាំ | ៩០៧ | ២ | ២០ | ២០ | ០ | ០ | ០ | ២ | ២០ | ២០ |
| មហាវិទ្យាល័យ | ១៨-៣៥ ឆ្នាំ | ២៨៦៣ | ៦ | ៦៣ | ៦៣ | - | - | - | | | |

ប្រភពទិន្នន័យ: ការគណនាតាមតំរូវការចំណោលប្រជាសាស្ត្រ

**យោលតាមបទដ្ឋានអប់រំ និងចំណោលប្រជាសាស្ត្រតាមអាយុ នៅឆ្នាំ២០២២**

**-សាលារៀនបឋមសិក្សាៈ**

- ១ខ្នង : មាន ៦បន្ទប់ ស្មើនឹង ៦ ថ្នាក់ (ពេលម៉ោង១ថ្ងៃ)
- ចំនួនសិស្សក្នុងថ្នាក់: ៤៥នាក់/ថ្នាក់ (គិតជាមធ្យម)

ដូច្នេះឆ្នាំ២០២២ តំរូវការសាលារៀន ចំនួន១ខ្នង ៧បន្ទប់ ។ សាលារៀនបឋមសិក្សាបច្ចុប្បន្នមាន ៧ខ្នងរួចហើយ ប៉ុន្តែ ស្ថានភាពសាលាចាស់ ដូចនេះឃុំសុំបញ្ចូលសំណើរសាងសង់អាគាថ្មី១ខ្នង ៧បន្ទប់ បន្ថែមទៀត ដែលត្រូវសាងសង់នៅលើដី សាលាបឋមសិក្សា ដែលមានស្រាប់ ។

**-អនុវិទ្យាល័យ និងវិទ្យាល័យៈ**

- ១ខ្នង : មាន ១២បន្ទប់ (អាគារពីរជាន់) ស្មើនឹង ១២ ថ្នាក់ (ពេលម៉ោង១ថ្ងៃ)
- ចំនួនសិស្សក្នុងថ្នាក់: ៤៥នាក់/ថ្នាក់ (គិតជាមធ្យម)

ផ្អែកតាមកំណើនសិស្សនៅឆ្នាំ២០២២ តំរូវការសាលារៀន ត្រូវសាងសង់សាលាអនុវិទ្យាល័យចំនួន១ និង វិទ្យាល័យ២ ។

ចំពោះតំរូវការសំរាប់ ការសិក្សាមហាវិទ្យាល័យ គឺគ្រាន់តែធ្វើការវិភាគអំពីតំរូវការ និង ការកើនឡើង នូវចំនួនសិស្សដែលបានបញ្ចប់ការសិក្សាវិទ្យាល័យប៉ុណ្ណោះ។ ពុំមានការវិភាគដើម្បីសាងសង់ សាលាសំរាប់មហាវិទ្យាល័យនៅមូលដ្ឋានស្រុក នេះទេ។

### ២.៣.៦ ឧស្សាហកម្ម

## ២.៤ តំបន់សើប

តំបន់មួយជ្រុងភាគខាងកើត ឈាងខាងត្បូង នៃឃុំនគរភាស ជាតំបន់គំរបព្រៃឈើរបស់រដ្ឋ ។ ការដណ្តើម កាន់កាប់ដីធ្លីដោយធ្វើ ការរុករានដីព្រៃ ឈើធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយម្យ៉ាងទៀតស្ថានភាពរំដើបរំជួលពីទីផ្សារដី អ្នកភូមិមួយចំនួន ឈ្មួញ លក់ដូរដីព្រៃដោយខុសច្បាប់ បានធ្វើឱ្យមានភាពអនាធិតេយ្យក្នុងការគ្រប់គ្រងដីព្រៃឈើរបស់រដ្ឋ ។

# ផែនទី តំបន់សើប ឃុំ នគរភាស

## HotSpot Map of Norkpr Phease Commune (170105)



## ២.៥ ការប្រឈម និង ឧបសគ្គ

ដោយស្វែងរកលាភសក្ការៈលើទីផ្សាដីធ្លី និង កង្វះខាតគោលគំនិតអភិរក្សព្រៃឈើ បានបង្កើនទូវនៅតំបន់ទំនាស់ដីធ្លីដែលមានរូបរាងជាលក្ខណៈគ្រួសារ និង ជាក្រុមមនុស្សមួយចំនួន ដែលជាករណីធ្វើអោយមានការរំលោភបំពានគ្នាទៅវិញទៅមក ដោយធ្វើការអះអាងតែភាពត្រឹមត្រូវរៀងៗខ្លួនមិនគោរពគោលការណ៍ច្បាប់ទំលាប់ឡើយ បញ្ហាទាំងនេះ ជាឧបសគ្គចំបង ដែលធ្វើអោយស្ថាប័នសមត្ថកិច្ច ចំណាយ ពេលវេលាច្រើន ក្នុងការសំរបសំរួល និង សូមអន្តរាគមន៏ពីស្ថាប័នពាក់ព័ន្ធ ថ្នាក់ខេត្ត និង ថ្នាក់ជាតិ ។

បញ្ហាព្រំព្រទល់នៅតែមិនទាន់បានធ្វើការដោះស្រាយបាននៅឡើយ ដោយអាជ្ញាធរប្រកាន់ទៅតាមទំលាប់របស់អ្នកភូមិ ពុំបាន រិះរកនូវគោលការណ៍ជាក់លាក់ និងសំណូមពរជួយដោះស្រាយពីគណៈកម្មាធិការដោះស្រាយព្រំប្រទល់រដ្ឋបាលឃុំ-សង្កាត់ ពីថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ ។

ប្រជាជនក្នុងឃុំ ស្ទើតែ ១០០ ភាគរយ កាប់ឈើធ្វើអុស ដើម្បីចំអិនអាហារប្រចាំថ្ងៃ ធ្វើឱ្យការកាប់ឈើមានការកើនឡើង រីឯការដាំដើមឈើឡើងវិញពុំទាន់បានផុលផុស ។

ការខ្វះប្រព័ន្ធធារាសាស្ត្រ ការខ្វះខាតពូជមានទិន្នផលខ្ពស់ ការខ្វះអ្នកបច្ចេកទេសផ្នែកកសិកម្មក្នុងឃុំ ដើម្បីបង្រៀនដល់កសិករ ក្នុងការបង្កើនទិន្នផលកសិកម្មឱ្យបានខ្ពស់ និងការហូរច្រោះដីមានជីជាតិពីស្រែ ដោយសារការកាប់បំផ្លាញព្រៃឈើ គឺមូលហេតុទាំងនេះហើយដែលធ្វើឱ្យផលិតផលកសិកម្មថយចុះ ។

បញ្ហាពុំទាន់មានផ្លូវក្រាលកៅស៊ូនៅក្នុងឃុំ ប្រជាពលរដ្ឋធ្វើដំណើរមានការលំបាក ជាពិសេសនៅរដូវវស្សា ។

សំរាប់សេវាសុខភាព មានមណ្ឌលសុខភាពតែមួយគត់ក្នុងឃុំ បើគួរមានមួយភូមិមួយ ។

ក្មេងគ្រប់អាយុចូលរៀនមិនបានចូលរៀនមានចំនួនច្រើន ពុំទាន់មានសាលាគ្រប់គ្រាន់នៅឡើយ ពុំទាន់មានមត្តេយ្យសាលា ដូចនេះផ្នែកសិក្សាធិការនៅក្នុងឃុំមានការខ្វះខាតនៅឡើយ ។

ប្រជាពលរដ្ឋពេញវ័យធ្វើការមួយចំនួនធ្វើចំណាកស្រុក ដើម្បីរកការងារធ្វើ ។

ពុំទាន់មានស្ថាប័នឯកជន វិរដ្ឋ មកវិនិយោគវិស័យកសិកម្មក្នុងឃុំនៅឡើយ ។

ត្រូវរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំឱ្យបានច្បាស់លាស់ ។

## តារាងទី២៤: បញ្ហាប្រឈម និងសក្តានុពល (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| ១.១. បញ្ហាប្រឈម និងសក្តានុពល (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ) ឃុំនគរភាស | | | |
|---|---|---|---|
| **បញ្ហា** | **ទីតាំងនៃបញ្ហា** | **មូលហេតុ** | **ដំណោះស្រាយ** |
| ១ | ២ | ៣ | ៤ |
| ១.ខ្វះដីស្រែ | -ភូមិទំពូង<br>-ភូមិកុក<br>-ភូមិថ្មី | ក.ប្រជាជនកើនឡើង.ដីតិច<br>ខ.ប្រជាជនកើនឡើង.ដីតិច<br>គ.ដីខ្សោះជីជាតិ | -ធ្វើជីកំប៉ុស្ត.ធ្វើដំណាំចំរុះ<br>-កែច្នៃដំណាំកសិកម្មចំរុះ<br>-បច្ចេកទេសធ្វើជីកំប៉ុស្ត |
| ២.ខ្វះប្រភពទឹក | -ភូមិថ្មី<br>-ភូមិល្មើក<br>-ភូមិរមៀត<br>-ភូមិជំពូង | ក.គ្មានទំនប់ទប់ទឹក.គ្មានប្រឡាយ<br>ខ.ត្រពាំងរាក់<br>គ.គ្មានស្រះតាមគ្រួសារខ្វះថវិកាជីកស្រះ | -ធ្វើទំនប់ទឹក.ជីក-ស្តារ ប្រឡាយ<br>-ស្តារត្រពាំងសាធារណៈនិងជីកស្រះសហគមន៍<br>-ជីកស្រះជាលក្ខណៈគ្រួសារ |
| ៣.ដីខ្វះជីជាតិ | -ភូមិជំពូង<br>-ភូមិល្មើក<br>-ភូមិរមៀត | ក.សំបូរដីខ្សាច់ច្រើន<br>ខ. សំបូរដីខ្សាច់ច្រើន<br>គ.ដីខ្ពស់-ដីខ្សាច់ | -លើកប្រព័ន្ធភ្លឺស្រែ. ធ្វើជីកំប៉ុស្ត<br>-បច្ចេកទេសធ្វើជីធម្មជាតិ<br>-កែច្នៃដីអោយបានរាបស្មើល្អ |
| ៤.ខ្វះផ្លូវធ្វើដំណើរ | -ភូមិល្មើក<br>-ភូមិរមៀត<br>-ភូមិជំពូង<br>-ភូមិនគរភាស | ក.ខ្វះថវិកា<br>ខ. ខ្វះថវិកា<br>គ. ខ្វះថវិកា | -ជួសជុល .ក្រាលគ្រួសក្រហម និងចាក់កៅស៊ូ |
| ៥.ខ្វះសាលារៀន | -ភូមិជំពូង<br>-ភូមិរមៀត<br>-ភូមិកុក | ក.សិស្សកើនឡើង | - សាងសង់សាលារៀនបន្ថែម |

ប្រភពទិន្នន័យ: ផែនការឃុំ

# ផែនទីបញ្ហា មូលហេតុ ដំណោះស្រាយ ឃុំនគរភាស

## Problem Cause Solution Map of Norkpr Phease Commune (170105)




**Legend**

- District office
- Commune Office
- Village
- Pagoda
- School
- Historical Site
- Health Center
- Hospital
- Sealed Road
- Laterite Road
- Rural Road
- Permanent River
- Seasonal Stream
- Canal
- Major Canal
- Levee
- District Boundary
- Commune Boundary
- Angkor Wat, Protected Landscape
- Beng Per, Wildlife Sanctuary
- Kulen Promtep, Wildlife Sanctuary
- Phnom Kulen, National Park
- Tonle Sap, Multiple Use
- Water Reserve
- Tonle Sap Lake

- 1200, Village Settlement
- 2110, Wet season rice
- 2400, Swidden
- 4200, Flooded Grass
- 4510, Abandoned field covered by shrub
- 5110, Lake

ខេត្តសៀមរាប

0 1,000 2,000
Meters

| | | |
|---|---|---|
| | : | UTM |
| | : | 48N |
| | : | WGS |
| | : | Everest |

### ២.៥.១ ការប្រឈមដោយធម្មជាតិ

ភាពរិចរិលនៃព្រៃធម្មជាតិ ដោយសារការកាប់បំផ្លាញខុសច្បាប់ តំរូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋយកឈើធ្វើអូសចំអិនអាហារ កំណើនប្រជាជននាំឱ្យតំរូវការពង្រីកដីស្រែចំការ លំនៅឋាន ត្រូវការដីបន្ថែមទៀត គឺដីព្រៃរិចរិល។ ទន្ទឹមនឹងនេះគ្រោះធម្មជាតិ អាកាសធាតុមានការប្រែប្រួលខុសរដូវកាល បណ្តាលអោយការធ្វើស្រែ ចំការ និង ដំណាំរួមផ្សំនានារង់ចាំតែទឹកភ្លៀង រងនូវគ្រោះការរាំងស្ងួត ការហូរច្រោះដីមានជីជាតិ ដោយសារការកាប់ព្រៃនៅផ្នែកខាងលើ នៅរដូវវស្សាមានទឹកច្រើនតែមិនបានសង់អាងស្តុកទឹកសំរាប់រដូវប្រាំង មូលហេតុខាងលើនាំឱ្យប៉ះពាល់ទិន្នផលកសិកម្ម ។

នៅរដូវវស្សា មានការជន់លិចដាច់ផ្លូវជាកំណាត់ៗ ដែលជាហេតុធ្វើអោយពិបាកក្នុងការធ្វើដំណើរទៅមក ។ តំបន់ស្រែចំការមួយចំនួនត្រូវរងគ្រោះទឹកជំនន់ជនលិច បណ្តាលអោយខូចខាតផលដំណាំរបស់ប្រជាពលរដ្ឋ។

កំណើនប្រជាជន មានសន្ទុះលឿនពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារតែ ប្រជាពលរដ្ឋនៅមូលដ្ឋាន ពុំទាន់យល់ពីការពន្យាកំនើត នាំឱ្យប្រជាពលរដ្ឋភាគច្រើនមានកូនច្រើន តំរូវការប្រចាំថ្ងៃខ្ពស់ តែបានចំណូលតិច។

### ២.៥.២ ការប្រឈមដោយការអភិវឌ្ឍន៍ដែលពុំមាន ចីរភាព (គ្មានផែនការទុក ជាមុន)

ជាការពិតណាស់ដោយគំរោងអភិវឌ្ឍន៍ពុំមានផែនការជាក់លាក់ និងការគិតពុំបានដល់វិសតល់ និងគ្រប់ជ្រុងជ្រោយនឹងជួបផលពិបាក ផលប៉ះពាល់ការ អភិវឌ្ឍន៍នាពេលអនាគត។ ការសិក្សាពីស្ថានភាពភូមិសាស្ត្រ ដើម្បីរៀបចំផែនការប្រើប្រាស់ដីក្នុងឃុំ ការសិក្សាពី ផលប៉ះពាល់សង្គម បរិស្ថានធម្មជាតិ សក្តានុពលរបស់ដែលមាន និងតំរូវការចាំបាច់ក្នុងមូលដ្ឋាន គឺជាគ្រឹះសំរាប់ការធ្វើផែនការអភិវឌ្ឍន៍ ឱ្យមាននិរន្តភាពយូរអង្វែង និងទទួលបានជោគជ័យ ។

## ២.៦ ឱកាស

### ២.៦.១ ដោយអំណោយផលធម្មជាតិ

ដើម្បីគ្រប់គ្រងធនធានធម្មជាតិដែលមាននូវសេសសល់ឱ្យបានល្អ ត្រូវមានការការពារ និងគ្រប់គ្រងអោយបានហ្មត់ចត់ ហើយត្រូវការចំបាច់ដាំដើមឈើឡើងវិញ ដោយប្រើនូវវិធានការច្បាប់ដែលមានស្រាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ទប់ស្កាត់ឱ្យបានដាច់ខាតរាល់ការកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់ និងកត្តាអំណោយផលធម្មជាតិ អាកាសធាតុយើងអាចថែរក្សាការពារព្រៃឈើ និងបរិស្ថានបានល្អ ដោយមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធនានា និងមានការចូលរួមពីប្រជាពលរដ្ឋក្នុងភូមិ ។

ហើយម្យ៉ាងទៀត ដីសំរាប់កសិកម្ម ដូចជា ដីស្រែ ចំការ នៅមានជីជាតិមធ្យមហើយ អាចធ្វើការកែសំរួលគុណភាពដីសមស្របតាមលក្ខណៈបច្ចេកទេសអោយបានល្អប្រសើរ ។

## ២.៦.២ ដោយបច្ចេកទេសថ្មី

បច្ចុប្បន្នប្រជាជន បានទទួលបានការបណ្តុះបណ្តាល ការរៀនសូត្រ ការផ្សព្វផ្សាយនូវបច្ចេកទេសជំនាញថ្មីៗជាច្រើន ដើម្បីបង្កើនការយល់ដឹង ផ្នែកកសិកម្ម តាមរយៈស្ថាប័នរដ្ឋ និងអង្គការនានា ដូចជា :

-ការដាំដុះតាមបែបកសិកម្មទំនើប មានប្រពលវប្បកម្ម កសិកម្មចំរុះ ការប្រើប្រាស់ជីធម្មជាតិ ។

-ការចិញ្ចឹមត្រីតាមបច្ចេកទេស មានលក្ខណៈជាគ្រួសារ និងជាកសិដ្ឋាន ។

-ការចិញ្ចឹមសត្វតាមលក្ខណៈបច្ចេកទេស មានដូចជា ជ្រូក មាន់ ទា គោ មានលក្ខណៈជាគ្រួសារ និងជាកសិដ្ឋាន ។

-វិធីសាស្ត្របង្កើត និងគ្រប់គ្រងសហគមន៍ព្រៃឈើ សហគមន៍នេសាទ និង សហគមន៍ប្រើប្រាស់ទឹក ។

-ការបំរើសេវាកម្ម សុខភាព និង វិធីសាស្ត្រការពារជំងឺឆ្លងនានា ។

-អំពីច្បាប់ភូមិបាល និងការចុះបញ្ជីជូនប្រជាពលរដ្ឋ ។

-បច្ចេកទេសផ្សេងៗទៀតដែលទាក់ទងទៅនឹងជីវភាពរស់នៅរបស់ប្រជាជន សន្តិសុខ និងសង្គម ។

## ២.៦.៣ ដោយគំរោងវិនិយោគ

ប្រជាពលរដ្ឋឃុំនគរភាស ភាគច្រើនបានចំណូលមកពីវិស័យកសិកម្ម និងគំរោងវិនិយោគឃុំមួយចំនួនតាមរយៈរាជរដ្ឋាភិបាល និងជំនួយពីអង្គការនានា ។ ចំណូលពីការងារនេះនៅមិនទាន់គ្រប់គ្រាន់ ដើម្បីបង្កើនប្រាក់ចំណូលប្រចាំថ្ងៃរបស់របជាពលរដ្ឋ ឃុំត្រូវការចាំបាច់រកដៃគូអភិវឌ្ឍន៍បន្ថែមទៀត ស្របតាមសក្តានុពលដែលឃុំមាន ដើម្បីធ្វើយ៉ាងណា រកការងារជូនប្រជាពលរដ្ឋក្នុងឃុំ កាត់បន្ថយចំណាក់ស្រុករបស់ប្រជាពលរដ្ឋ និងម្យ៉ាងទៀតឃុំក៏ទទួលបាននូវប្រាក់ចំណូល តាមរយៈបង់ពន្ធ ដើម្បីកសាង និងអភិវឌ្ឍន៍ឃុំឱ្យបានរីកចំរើន ។

# ជំពូក៣

# ផែនការប្រើប្រាស់ដីនាពេលអនាគតឆ្នាំ២០០៩_២០២២

## ៣.១ ការប្រើប្រាស់ដីសំរាប់ពេលអនាគត

ផ្ទៃដីនៅក្នុងឃុំ ចែកចេញជាពីរតំបន់ គឺតំបន់វាលទំនាប និងតំបន់ខ្ពង់រាប មួយភាគធំបំរើអោយវិស័យកសិកម្ម និងផលិតកម្មដំណាំឧស្សាហកម្ម ហើយនៅមានសក្តានុពល ដោយដីមួយចំនួននៅមានដីជាតិគ្រប់គ្រាន់ និងមួយចំនួនទៀតទើបតែត្រូវបានប្រើប្រាស់ សំរាប់បំរើវិស័យនេះ។ ភាពខ្សោះជីជាតិមានជាមធ្យម ហើយការគាំទ្រសមស្របតាមលក្ខណៈបច្ចេកទេសកសិកម្ម ដូចជា រៀបចំប្រព័ន្ធភ្លឺស្រែ បិទស្នាក់ទប់ស្នាមភ្លោះ និងរៀបចំផែនការប្រើប្រាសដី នៅមានកំរិត។

នៅក្នុងឃុំ នៅឆ្នាំ២០០៨ មានប្រជាជនចំនួន ១៤៨៣ គ្រួសារ (៨៩៣៤ នាក់) ហើយនៅឆ្នាំ២០២២ គ្រោងនឹងកើនឡើងដល់ ១ ៨៣៨គ្រួសារ (១០ ៤៧៧ នាក់) ដែលបញ្ហានេះចាំបាច់ត្រូវឱ្យមានការគិតគូរឱ្យបានល្អិតល្អន់អំពី ផែនការប្រើប្រាស់ដីនាពេលអនាគត ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍន៍ប្រកបដោយចិរភាព ចូលរួមកាត់បន្ថយភាពក្រីក្រ និងទំនាស់ផ្សេងៗពាក់ព័ន្ធការប្រើប្រាស់ដី។

ឆ្លងតាមពត៌មាន និងទិន្នន័យ ដូចបានរាយរាប់ក្នុងជំពូក១ និងការវិភាគពីសក្តានុពល ឧបសគ្គ និងតម្រូវការដូចបាន បរិយាយក្នុងជំពូក២ តម្រូវការដីសំរាប់ប្រើប្រាស់នាពេលអនាគត និងសង្ខេបដូចក្នុងតារាងឧបសម្ពន្ធ័ទី២។

**តារាងទី២៥: តម្រូវការនៃការប្រើប្រាស់ដី អនាគតឆ្នាំ២០២២**

| ការប្រើប្រាស់ដីធ្លី | ក្រឡាផ្ទៃឆ្នាំនេះ(ហិកតា) | ក្រឡាផ្ទៃ១៥ឆ្នាំ(ហិកតា) | បំរែបំរួល (ហិកតា) |
|---|---|---|---|
| ដីភូមិ | ៣៧៩,៧ | ៤៧១,៧ | ៩២ |
| ដីវាលស្រែ | ៣៩៥០ | ៤១៥០ | ២០០ |
| ដីចំការដំណាំ | - | - | - |
| ដីសហគមន៍ព្រៃឈើ | - | - | - |
| ដីសហគមន៍នេសាទ | - | ១៤,៥៦ | ១៤,៥៦ |
| ដីសម្បទានសង្គមកិច្ច | - | - | - |
| ដីស្រោចស្រព | - | ៥០ | ៥០ |
| ដីដំណាំរយៈពេលខ្លី | - | ៥ | ៥ |
| ដីចំការដំណាំឈើហូបផ្លែ | - | - | - |
| ដីតំបន់អភិរក្ស | - | - | - |
| តំបន់ទេសចរណ៍បរិស្ថាន | - | - | - |
| ដីចំការឈើធំៗ | 0 | - | - |
| ដីវាលកប់ខ្មោច | 0 | - | - |
| កន្លែងចាក់សំរាម | 0 | ១ | ១ |

ប្រភពទិន្នន័យ:ផែនការតំរូវការរបស់ឃុំ

- **ផែនទីប្រើប្រាស់ដីអនាគត**

តាមរយៈពត៌មាន និងទិន្នន័យដូចបានរាយរាប់ក្នុងជំពូក១ ការវិភាគពីសក្តានុពល ឧបសគ្គ និងតម្រូវការដូចបាន បរិយាយក្នុងជំពូក២ តារាងតម្រូវការដីតាមប្រភេទនៃការប្រើប្រាស់នាពេលអនាគត ការវិភាគពីប្រព័ន្ធអេកូឡូស៊ី និង ភូមិសាស្ត្រ និងតាមរយៈចំណេះដឹងនៅមូលដ្ឋានរបស់ប្រជាពលរដ្ឋ ផែនទីប្រើប្រាស់ដីអនាគតឆ្នាំ២០២២ ត្រូវបានព្រាង ឡើង ដូចមានបង្ហាញឧបសម្ព័ន្ធ។

## ៣.២ បញ្ញត្តិលើការប្រើប្រាស់ដី

ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងកិច្ចការពារបរិស្ថាន ដើម្បីលើកកំពស់ជីវភាពរស់នៅ និង គ្រប់គ្រងធនធានធម្មជាតិ ឱ្យកាន់តែប្រសើរឡើង ភ្នាក់ងាររាជរដ្ឋាភិបាល ជាពិសេសអាជ្ញាធរមូលដ្ឋាន ត្រូវទទួលខុសត្រូវ រាល់សកម្មភាពអនុវត្តន៍ វិធានការការពារ ការគោរពច្បាប់ និងបទបញ្ញត្តិ ចំពោះប្រភេទនៃការប្រើប្រាស់ដីនីមួយៗ។ មាន សកម្មភាពជាច្រើនដែលត្រូវជំរុញឱ្យអនុវត្ត និងសកម្មភាពមួយចំនួនទៀតដែលត្រូវធ្វើការហាមឃាត់ និងមានពេលខ្លះក៏ ទាមទារឱ្យមានការការពារពិសេសផងដែរ ឧទាហរណ៏: សំរាប់តំបន់លំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធសមស្របសំរាប់ទ្រទ្រង់ ជីវិតរស់នៅរបស់ប្រជាពលរដ្ឋ (ប្រព័ន្ធផ្លូវគមនាគមន៍ ទឹកស្អាត សំណល់រាវ អគ្គិសនី ...) ត្រូវធ្វើឱ្យប្រសើរឡើង និងត្រូវការពារតំបន់ហាមឃាត់ និង តំបន់បំរុងទុកសំរាប់សេវាសាធារណៈនាពេលអនាគត (ផ្សារ មន្ទីរពេទ្យ សាលារៀន...)។ វិធានការកែលំអ និងលើក កំពស់គុណភាពផលិតផលកសិកម្ម និងសេវាកម្មទីផ្សារ ត្រូវបានលើកទឹកចិត្ត ជំរុញឱ្យអនុវត្ត និងត្រូវធ្វើអោយប្រសើរ ឡើង។ សំរាប់ផ្នែកព្រៃឈើ ត្រូវទប់ស្កាត់ ហាមឃាត់រាល់សកម្មភាពកាប់ទន្រ្ទាន ព្រៃ ហើយការដាំដើមឈើឡើងវិញនៅ តំបន់ការពារ និងវិធានការការពារ ការហូរច្រោះ គប្បីត្រូវដាក់ជំរុញឱ្យអនុវត្ត។

រាល់ការបម្លែងដី សិទ្ធិក្នុងការកាន់កាប់ ការបែងចែក មុខសញ្ញាទទួលផល រួមទាំងនីតិវិធីទាំងឡាយ ត្រូវអនុវត្ត និងត្រូវគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន ។

### ៣.២.១ ដីលំនៅស្ថានថ្មី

**ក្បាល់ដីលេខ: F1200-01**

ដីនេះមានទំហំ នៅទូទាំងឃុំមានការរីកស្រេបអមនៅសង្ខាងផ្លូវ ដែលតភ្ជាប់ពីភូមិមួយទៅភូមិមួយមាន ទទឹងប្រមាណជា ២០០មែត្រ ១០០មែត្រអមសង្ខាងផ្លូវ ។ បច្ចុប្បន្នជាដីស្រែវស្សា ដែលមានផ្លូវលំដីស+ដីក្រហម ឆ្លងកាត់ហើយដីនេះវាមិនមែនជាដីស្រែជំរៅ ជារៀងរាល់ឆ្នាំ ការសាងសង់ផ្ទះនៅពេលដែលមានការបែកចេញពី គ្រួសារ ទៅតាំងលំនៅស្ថានថ្មី ទៅតាមលទ្ធភាពដែលពួកគាត់មាន។

ដីស្រែវស្សា គឺជាកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ នៅតភ្ជាប់ពីចុងភូមិ ហេតុនេះដីនេះមិនត្រូវបានកំណត់ នៅក្នុងការកំណត់មុខសញ្ញា អោយបានច្បាស់លាស់ឡើយ។ តែដីដែលមាននូវអមសង្ខាងផ្លូវលំ តាមបណ្តោយ

គឺជាដីដែលត្រូវធ្វើការសាងសង់លំនៅស្ថាន សំរាប់ការរីកសាយ របស់កូនចៅអ្នកភូមិ ដែលត្រូវបែកចេញជាគ្រួសារថ្មីនិងជាម្ចាស់កម្មសិទ្ធិស្រេច ឬ ក៏ធ្វើឡើងតាមរយៈការដោះដូរ ឬ ទិញលក់តាមការព្រមព្រៀងគ្នារវាងអ្នកភូមិ ។

**បញ្ញាត្តិក្នុងការប្រើប្រាស់ដីគឺ:**

- ត្រូវរក្សាទុកដីចំណីផ្លូវ តាមច្បាប់កំណត់ ទៅតាមប្រភេទដីនីមួយៗ
- ជំរូវសំរាប់លំនៅឋានមិនអាចលើសពី ១០០ម៉ែត្រ គិតពីអ័ក្សផ្លូវ ។
- មិនអនុញ្ញាត្តិអោយធ្វើការទិញលក់ដីចំណីផ្លូវ
- ត្រូវរក្សាទុកចំណីស្ទឹង តាមច្បាប់កំណត់៖ ចំងាយ ១៥ មែត្រ គិតពីមាត់ច្រាំងនូវរដូវប្រាំង ៉

ចំពោះក្បាលដីទាំងនេះស្ថិតនៅស្របអមសង្ខាងផ្លូវតាមបណ្តាភូមិទូទាំងឃុំ ដែលទទឹងប្រមាណជាង ២០០មែត្រ ។ បច្ចុប្បន្នដីនេះជាដីស្រែស្រូវវស្សា ហើយលិចទឹកតែរដូវវស្សាដែលមានជំរៅរាក់ពី ៣០ ទៅ ៥០ សង្ទីម៉ែត្រ តែមួយរយៈពេលខ្លីប៉ុនណ្ណោះ។ នៅទូទាំងឃុំនេះ ក៏មានគំរេងលើកផ្លូវលំដីស និងជួសជុលតភ្ជាប់ពី ផ្លូវលំស្រាប់ ស្របតាមភូមិមួយចំនួន ដូចនេះលំនៅស្ថានកើតឡើងតាមបណ្តោយដងផ្លូវទាំងនេះដោយពុំទាន់មាន ការខ្វះខាត់ដី តំរូវការធ្វើសម្បទាសង្គមកិច្ចចំពោះគ្រួសារដែលមានកង្វះខាត់តិចតួចនោះព្រោះអ្នកភូមិអាចធ្វើការ ទិញលក់រវាងពួកគេ។

### ៣.២.១ ដីកសិកម្មថ្មី

**ក្បាល់ដី: F2110-01**

ដីនេះមានទំហំ ២០០ ហ.ត ជាដីព្រៃរិចរិលបន្តភ្ជាប់ពីចុងភូមិទៅប៉ែកខាងកើត បច្ចុប្បន្ននេះអ្នកភូមិធ្វើការកាប់ចំការស្រូវ ។ ដោយដីនេះ ជាដីព្រៃឈើ ព្រៃឈើផ្សេងៗមួយចំនួន ៥៧៨ ហ.ត ដូច្នេះដីនេះជាគោលដៅសំរាប់ធ្វើសម្បទានសង្គមកិច្ច សំរាប់កំណើនគ្រួសារ ដែលមានកង្វះខាតដីកសិកម្ម តិចជាង ១ ហិចតា។

**បញ្ញាត្តិក្នុងការប្រើប្រាស់ដីគឺ:**

- អនុវត្តន៍សម្បទានដីសង្គមកិច្ចសំរាប់ចំណែក ដែលជាដីរដ្ឋ
- មិនត្រូវជីកស្រះ ឬ លើកជាទំនប់ស្ទាក់ទឹក ជាទ្រង់ទ្រាយធំ
- ហាមដាច់ខាតមិនអោយប្រើប្រាស់ ថ្នាំពុល ដើម្បីបំពុលសត្វល្អិត។

### ៣.២.៣ ហេដ្ឋារចនាសម្ពន្ធ័ ( ផ្លូវ )

**ក្បាល់ដី: FRD4,5-01**

ជាទូទៅនៅក្នុងឃុំ មានគំរោងផ្លូវលំដីស ដីក្រហម និងផ្លូវក្រាលកៅស៊ូ ដែលមានប្រវែងសរុប ៣១.៤ គីឡូម៉ែត្រ ដោយត្រូវធ្វើការសាងសង់ថ្មីនិង ធ្វើការជួសជុលបំពេញបន្ថែម មានទាំងការរៀបចំប្រព័ន្ធលូ ស្ពាន ទៅតាមទម្រង់ភូមិសាស្រ្តនិង បែបបទបច្ចេកទេស ដើម្បីទ្រទ្រង់គុណភាពផ្លូវ អោយមាននិរន្តភាព។ ដោយដីនេះ ជាដីសាធារណៈរបស់រដ្ឋ ការរៀបចំសាងសង់គឺត្រូវអនុវត្តន៍ ទៅតាមបទដ្ឋានបច្ចេកទេសខ្ពស់ បើមិនមានការគិតគូរ អោយមានការហួតចត់

នោះទេ ការរង់គ្រោះដោយទឹកជំនន់ ការទ្រទ្រង់ក្នុងការប្រើប្រាស់ធ្វើអោយមានការខាតបង់ ថវិកា និងពេលវេលា ក្នុងការទំនាក់ទំនងទៅមក។

បញ្ញាត្តិក្នុងការប្រើប្រាស់គឺ

- មិនត្រូវយកដីចំណីផ្លូវប្រើប្រាស់ជាឯកជន ១ កម្មសិទ្ធឯកជន ៤

- ហាមដាច់ខាតការទិញលក់ដីចំណីផ្លូវ

### ៣.២.៤ ប្រពន្ធ័ប្រឡាយ

**ក្បាល់ដីលេខ: FDN57-01**

- ប្រព័ន្ធប្រឡាយចែកចេញពីរប្រភេទផ្សេងៗគ្នា គឺប្រភេទប្រឡាយមេ និងប្រភេទប្រឡាយរងមានចំនួន ៨ ខ្សែ ប្រវែងសរុប ១៩.៤ គីឡូម៉ែត្រ ដែលប្រឡាយមេមួយខ្សែមានប្រវែង ១១.៤ គីឡូម៉ែត្រ ជាទំរងប្រឡាយចាស់មានស្រាប់តែប្រព័ន្ធប្រឡាយនេះ គឺមានលទ្ធភាពជួយអោយវិស័យកសិកម្មនារដូវវស្សា ដែលទទួលប្រភពទឹកពីឃុំដូនពេង+ឃុំគោកដូង។ ប្រឡាយរងក្នុងចំនួន ៨ខ្សែ គឺវាជួយនាំទឹកទៅអោយតំបន់ដីស្រែមួយចំនួនងាយរង និងភាពរាំងស្ងួត ជាករណីចាំបាច់ដែលត្រូវតែធ្វើការអភិវឌ្ឍន៍ពីតំបន់ដែលមានប្រភពទឹក។

បញ្ញាត្តិក្នុងការប្រើប្រាស់គឺ :

- បង្កើតផ្លូវថ្មើរជើងលើប្រព័ន្ធប្រឡាយ

- មានលក្ខន្តិកៈសហគមន៍ប្រើប្រាស់ទឹក

### ៣.២.៥ បឹង ត្រពាំង

**ក្បាល់ដី: F5130-01**

-បឹង, ត្រពាំងជាទ្រព្យសម្បត្តិសាធារណៈ ដែលនៅក្នុងទូទាំងឃុំបានថែរក្សាការពារទុកប្រើប្រាស់ជាសហគមន៍សរុបទាំងអស់មាន ៨ កន្លែង ដែលមានផ្ទៃសរុប ២៣.៩៣ ហ.ត និងជាអាងស្តុកទឹកសំរាប់ជំនួយដល់ភាពរាំងស្ងួតព្រមទាំងជួយដលការស្រោចស្រពផលិតផលកសិកម្មនារដូវប្រាំង និងជាគោដៅអនាគត ធ្វើការស្តាឡើងវិញដើម្បីជាផលប្រយោជន៍សង្គម។

បញ្ញាត្តិក្នុងការប្រើប្រាស់គឺ:

- មានលក្ខន្តិកៈសហគមន៍ប្រើប្រាស់ទឹក

- ហាមមិនឱ្យជីកកាយស្រះទឹកជាលក្ខណៈឯកជន

- ហាមការវាតដីយកធ្វើកម្មសិទ្ធិ

## ៣.៣ ការវាយតំលៃនៃការប្រើប្រាស់ដី

- **ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ**

ការប្រើប្រាស់ដីនៅក្នុងតំបន់និមួយៗ គឺពុំមានលក្ខណៈដូចគ្នា ដែលចាំបាច់ត្រូវផ្អែកលើលក្ខណៈសម្បត្តិធនធានធម្មជាតិ ស្ថានភាពភូមិសាស្ត្រ និងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។ បច្ចុប្បន្ននេះ ផ្ទៃដីនៅក្នុងឃុំ ប្រមាណជា ៥៧% ត្រូវបានប្រើប្រាស់សំរាប់ធ្វើស្រែវស្សា ២២%ជាដីព្រៃដុះឡើងវិញ ១៥%ជាចំការបោះបង់ដុះព្រៃគម្ពោត និងដុះវាលស្មៅ។ ប៉ុន្តែនៅពេលអនាគត ដោយសារកំណើនប្រជាពលរដ្ឋ ដីព្រៃដុះឡើងវិញ ដីចំការបោះបង់ដុះព្រៃគម្ពោត និងដុះវាលស្មៅ អាចជាមុខសញ្ញានៃការពង្រីកផ្ទៃដីសំរាប់ធ្វើស្រែ និងចំការ ដែលបញ្ហានេះចាំបាច់ត្រូវគិតគូរឱ្យបានល្អពីស្ថានភាពអេកូឡូស៊ី និងភូមិសាស្ត្រ ដើម្បីលើកកំពស់ទិន្នផលកសិកម្ម និងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ។

- **គុណសម្បត្តិ និងគុណវិបត្តិក្នុងការផ្លាស់ប្តូរ**

ជាទិសដៅសំរាប់ការអភិវឌ្ឍន៍ឃុំក្នុងឆ្នាំ២០០៩-២០២២គោលដៅអភិវឌ្ឍន៍ចំបងគឺលើវិស័យកសិកម្ម ព្រោះវិស័យនេះគឺជាវិស័យស្នូលសំរាប់លើកកំពស់ជីវភាពប្រជាពលរដ្ឋ ហើយដែលមកទល់ពេលនេះ ក៏នៅតែពុំទាន់មានភាពជឿនលឿនផ្នែកផលិតកម្មនៅឡើយ។ វិស័យផ្សេងៗទៀតក៏ត្រូវបានយកមកគិតគូរ ហើយក៏ត្រូវបានបង្កើនការគ្រប់គ្រងឱ្យបានរឹងមាំបន្ថែមទៀតដែរ។

- **ផលប៉ះពាល់បរិស្ថាន សង្គម សេដ្ឋកិច្ច**

ជាការពិតហេដ្ឋារចនាសម្ព័ន្ធវាជាគោលដៅទៅលើការប្រើប្រាស់ដី តែវាពុំបានធ្វើអោយមាន ផលប៉ះពាល់ធ្ងន់ធ្ងរខាតបង់ក្នុងការធ្វើផលិតកម្ម កសិកម្មនោះទេ ព្រោះវាមានទំនាក់ ទំនងគ្នាទៅវិញ ទៅមកក្នុងការសំរួលចរាចរ ឆ្លងកាត់ និងការដឹកជញ្ជូនផងការផ្តល់នូវសេវាសាធារណៈ ។

## ៣.៤ ដំណោះស្រាយផ្សេងៗក្នុងករណីខ្វះខាតដី

បច្ចុប្បន្នតុល្យភាពរវាងមនុស្សនិងដី ពុំទាន់យកមកជាដំណោះស្រាយបញ្ហាលើ កង្វះខាតដីនោះទេ សំរាប់គោលដៅទៅអនាគតអាចនិងកើតមានឡើងដោយសារកំណើនមនុស្ស ដូចេះនៅលើផែនទីប្រើប្រាស់ដី គឺបានធ្វើ ការកំណត់ជាតំបន់ដីព្រៃមួយភាគ ដែលជាប្រភេទដីព្រៃឈើផ្សេងៗ នៅប៉ែកខាងកើតទីតាំងឃុំ។

ដើម្បីឱ្យមានស្ថេរភាពដីធ្លីទៅតាមគោលការណ៍កំណត់ ថ្វីត្បិតតែដីព្រៃទាំងនេះបានកំពុងមានការរិចរិលជាបន្តបន្ទាប់ទៅក៏ដោយហើយអ្នកភូមិបានធ្វើការគ្រប់គ្រងមែនពិត នោះជាដំណោះស្រាយដ៏ល្អនោះគឺ ធ្វើការទប់ ស្កាត់ការកាប់បំផ្លាញ ព្រៃឈើយកមកធ្វើកម្មសិទ្ធិដោយខុសច្បាប់ ហើយត្រូវធ្វើការដាំដុះព្រៃឈើឡើងវិញ និង ធ្វើការទប់ស្កាត់ទំនាស់ដណ្តើមកាន់កាប់ដីធ្លីធ្វើកម្មសិទ្ធិ។

ឃុំនេះជាឃុំមួយដែលមានវិសាលភាពផ្ទៃដីតូច ប្រជាកសិករ ៩៨% ជាអ្នកប្រកបមុខរបរកសិកម្ម ដូច្នេះកំណើនគ្រួសារនិង មានតំរូវការដីធ្លីបន្ថែម ដោយគ្រោងដីសម្បទាន សង្គមកិច្ច ពីតំបន់ព្រៃរិចរិល និងធ្វើ ប្រពលវប្បកម្ម បង្កើនទិន្នផលស្រូវ និង បង្កើនរដូវ ។

ដើម្បីអោយមានស្ថេរភាពទៅអនាគតតាមគោលការណ៍កំណត់ យើងត្រូវអភិវឌ្ឍន៍តាមទិសដៅ អភិវឌ្ឍន៍ដែលយើងបានកំណត់លើផែនទីប្រើប្រាស់ដី គឺបង្កើនគុណភាពដី និងប្រព័ន្ធស្រោចស្រព បង្កើនទិន្នផល ផលិតផល កសិកម្មអោយបានខ្ពស់ ។

## ៣.៥ កត្តាចាំបាច់សំរាប់ធានានិរន្តរភាព

### ៣.៥.១ កត្តាចាំបាច់សំរាប់ធានានិរន្តរភាព

ចាំបាច់ណាស់សំរាប់ការធានានិរន្តភាពចំពោះការគ្រប់គ្រង ប្រើប្រាស់ដីក្នុងឃុំទៅ តាមផែនការដែលបានគ្រោងទុក ប្រពន្ធ័កសិកម្មត្រូវតែធ្វើការអភិវឌ្ឍន៏អោយបានឆាប់រហ័ស និង ចំគោលដៅ ។

ធ្វើការផ្សព្វផ្សាយច្បាប់នានាដែលពាក់ព័ន្ធធនធានធម្មជាតិ តំបន់ការពារនិងធ្វើការបោះ បង្គោលព្រំអោយបានច្បាស់លាស់ និងការចូលរួមបង្កើតសហគមន៏ព្រៃឈើដោយអ្នកភូមិ ដើម្បីដឹកដៃ ពួកគាត់ដើរអោយចំគោលដៅពិតប្រាកដ បើពុំនោះទេភាពមិនច្បាស់លាស់នៅតំបន់ការពារណាមួយ អាចនិងធ្វើអោយមាន ការភាន់ច្រឡំក្នុងការប្រើប្រាស់ដីធ្លី ។

### ៣.៥.២ គំរោងគាំទ្រចាំបាច់នានាសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព

គំរោងគាំទ្រចាំបាច់ធានាសំរាប់ការអភិវឌ្ឍន៏ប្រកបដោយចីរភាពយូរអង្វែងបើសិនជា យើងដើរជើងតែម្ខាងនោះវាពុំងាយ និងដល់គោលដៅនោះឡើយ ។ដីធ្លីដែលជាគោលដៅអភិវឌ្ឍន៏វាជា ការលំបាកក្នុងការបង្កើតវា ភាពអសកម្មនៅជ្រុងណាមួយនៃគោលដៅដោយមិនបានគ្រោងផែនការ ទុកជាមុនដោយល្អិតល្អន់ ។

## ៣.៦ ការសន្និដ្ឋានជារួមលើផែនការប្រើប្រាស់នាពេលអនាគត

ផែនការប្រើប្រាស់ដី អនាគតឃុំ នគរ ភាស ២០០៩-ឆ្នាំ២០២២ ជាឧបករណ៏មួយដ៏សំខាន់ដែលជួយដល់ឃុំ និងប្រជាពលរដ្ឋនៅមូលដ្ឋានផ្ទាល់ ក៏ដូចជាដល់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព សមស្របនិង សមធម៌ ។ ការពិត ដីធ្លីគឺជាកត្តាស្នូលនៃការអភិវឌ្ឍន៏ សេដ្ឋកិច្ច សង្គម និងលើកដំកើងជីវភាពប្រជាពលរដ្ឋ ដូច្នេះក្រោយមានផែនការប្រើប្រាស់ដីនេះ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់ដីទៅក្នុង ផែនការអភិវឌ្ឍន៏ សេដ្ឋកិច្ច សង្គមកិច្ច ថ្នាក់មូលដ្ឋានដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ឃុំ ស្រុក និងការអនុម័តនៅថ្នាក់ខេត្ត តាមនីតិវិធី ដូចដែលធ្លាប់អនុវត្តក្នុងការការកសាងផែនការអភិវឌ្ឍន៏សេដ្ឋកិច្ច សង្គមកិច្ច កន្លងមក ដោយមាន ការចូលរួមពីគ្រប់ ភាគីពាក់ព័ន្ធនានា ក្នុងការអនុម័តសំរេច ។ គំនិតផ្តួចផ្តើមការងារ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់ ក្រុម ប្រឹក្សាឃុំ ក្រោមជំនួយបច្ចេកទេសរបស់ក្រុមការងារក្លួប ថ្នាក់ស្រុក និង សមាសភាគរៀបចំដែនដីថ្នាក់ខេត្ត របស់មន្ទីររៀបចំដែនដី

នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប ដោយមាន កិច្ចគាំទ្រថវិកា ដោយ DANIDA/DFID/NZAid ឃុំបានសំរេចនូវ សមិទ្ធិផល **សៀវភៅ ផែនការ ប្រើប្រាស់ដី អនាគត ២០០៩-២០២២** នេះឡើងដើម្បីគាំទ្រដល់ដំណើការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ (រយះពេលប្រាំឆ្នាំ) រហូតដល់ឆ្នាំ២០២២ និងកម្មវិធីវិនិយោគឃុំ សង្កាត់ (រយះពេលមួយឆ្នាំ) ដូចមានចែងនៅក្នុង អនុក្រឹត្យស្តី ពីនិតិវិធីនៃ ការរៀបចំផែនការ ប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។ សមិទ្ធិផល នៃដំណើរការរៀបចំផែនការនេះ គឺ "ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់" ។

ក្នុងករណីចាំបាច់ដែលមានការតំរូវការងារអភិវឌ្ឍន៍ពីរាជរដ្ឋាភិបាលផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ អាចកែប្រែបានតាមការសំរេចរបស់រាជរដ្ឋាភិបាល ដូចបានចែងក្នុងអនុក្រឹត្យ លេខ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ជំពូកទី ៦ មាត្រា ១៨ ។

ឃុំនគរភាស ថ្ងៃ 11 ខែ 12 ឆ្នាំ 2009

មេឃុំ

ថោង ធន់

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូន ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តសៀមរាប

"ដើម្បីមេត្តាពិនិត្យ និងសំរេច"

អង្គរជុំ ថ្ងៃ 21 ខែ 12 ឆ្នាំ 2009

**អភិបាលនៃគណៈអភិបាលស្រុក**

**និងជាប្រធានក្រុមការងារដីរដ្ឋ**

**ស្រុកអង្គរជុំ**

**បានឃើញ និង ឯកភាព**

សៀមរាប ថ្ងៃ ២៣ ខែ ធ្នូ ឆ្នាំ ២០១០

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ**

**ខេត្តសៀមរាប**

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ទី១: តារាងបញ្ជីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋក្នុងឃុំ

ឧបសម្ព័ន្ធ ទី២: តារាងផែនការអនាគត ១៥ឆ្នាំ

ឧបសម្ព័ន្ធ ទី៣: ផែនទីប្រើប្រាស់ដីអនាគតឆ្នាំ២០០៩_២០២២

ឧបសម្ព័ន្ធ ទី៤: ផែនទីគំរបព្រៃឈើ ឆ្នាំ២០០២ និង ផ្ទៃដី

ឧបសម្ព័ន្ធ ទី៥: រូបថតសកម្មភាពការងារចុះមូលដ្ឋាន

# តារាងបញ្ជីទ្រព្យឯកជនរបស់រដ្ឋក្នុង ឃុំ នគរភាស

| ល.រ | ឈ្មោះ | ភូមិ | ទំហំផ្ទៃដី | X | Y | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | សាលាបឋមសិក្សាគោកថ្មី | គោកថ្មី | 40m x 60m | 360542 | 1511654 | |
| ២ | អនុវិទ្យាល័យ នគរភាស | នគរភាស | 90m x 100m | 362194 | 1509720 | |
| ៣ | សាលាឃុំនគរភាស | នគរភាស | 7000m² | 362447 | 1509027 | |
| ៤ | គណបក្សប្រជាជនឃុំ | ល្បើក | 30m x 60m | 362499 | 1509056 | |
| ៥ | ប៉ុស្តិ៍ប៉ូលីស | ល្បើក | 30m x 40m | 362488 | 1509127 | |
| ៦ | ត្រពាំងល្បើក | ល្បើក | 80m x 100m | 363182 | 1509189 | |
| ៧ | សាលាបឋមសិក្សាល្បើក | ល្បើក | 50m x 70m | 362866 | 1509339 | |
| ៨ | ត្រពាំងរមៀត | រមៀត | 48m x 58m | 361897 | 1507746 | |
| ៩ | ត្រពាំងទំពូង | ទំពូង | 50m x 70m | 361522 | 1505989 | |
| ១០ | ត្រពាំងនគរភាស | នគរភាស | 250m x 700m | 361183 | 1504332 | |
| ១១ | វត្តនគរភាស | នគរភាស | 150m x 200m | 361821 | 1504661 | |
| ១២ | សាលាបឋមសិក្សានគរភាស | នគរភាស | 50m x 70m | 360950 | 1504003 | |
| ១៣ | សាលាបឋមសិក្សាពង្រ | ពង្រ | 50m x 60m | 359840 | 1506382 | |
| ១៤ | ត្រពាំងស្វាយ (ទន្លេស) | ទន្លេស | 60m x 60m | 359515 | 1507857 | |
| ១៥ | ត្រពាំងល្បើក (ទន្លេស) | ទន្លេស | 90m x 100m | 359448 | 1508236 | |
| ១៦ | សាលាបឋមសិក្សាទន្លេស | ទន្លេស | 50m x 60m | 359019 | 1508079 | |
| ១៧ | មន្ទីរពេទ្យទន្លេស | ទន្លេស | 30m x 50m | 358983 | 1508182 | |
| ១៨ | ចំណុចភូមិគោកថ្មី | គោកថ្មី | | 360899 | 1508182 | |

## ឧបសម្ព័ន្ធ ២

## បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ នគរភាស ក្នុងរយៈពេល ១៥ឆ្នាំ

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១[១] | ៥ឆ្នាំទី២[២] | ៥ឆ្នាំទី៣[៣] | |
| ២.៦.១. | គំរោងផ្នែកហេដ្ឋរចនាសម្ព័ន្ធ | | | | | | |
| | **២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** | | | | | | |
| | **១.១. ផ្លូវថ្នល់** | | | | | | |
| | ១.១.១. ផ្លូវក្រាលកៅស៊ូ | ៨,១ | គម | ២,៧ | ០ | ៥,៤ | |
| | ១.១.២. ផ្លូវក្រាលគ្រួសក្រហមនិងជួសជុល | ១៩,៣ | គម | ៧,៣ | ៦ | ៦ | |
| | ១.១.៣. ប្រវែងផ្លូវក្រាលដីស | ៤ | គម | ១,២ | ២,៨ | ០ | |
| | ១.១.៤. ផ្លូវរទេះ/ថ្មើជើង | | | | | | |
| | **១.២. ប្រព័ន្ធស្រោចស្រព** | | | | | | |
| | ១.២.១. ប្រឡាយមេ | ១១,៤ | គម | ៦,៦ | ១,៦៥ | ៣,១៥ | |
| | ១.២.២. ប្រឡាយរង | | | | | | |

(១) - ៥ឆ្នាំទី១ (២០០៨-២០១២)៖ បញ្ចូលគំរោងទាំងអស់របស់ **CDP** ឆ្នាំ ២០០៨-២០១២ រួមទាំងគំរោងផ្នែកប្រើប្រាស់ដីដែលបានបង្កើតក្នុង **CLUP** ផងដែរ (៥ ឆ្នាំទី១)

(២) - ៥ឆ្នាំទី២ (២០១៣-២០១៧)៖ គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្ត (៥ ឆ្នាំទី២)

(៣) - ៥ឆ្នាំទី២ (២០១៨-២០២២)៖ គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្តទៀត (៥ ឆ្នាំទី៣)

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត** | | | | | | |
| | ១.៣.១. ចំនួន ស្ពានថ្ម | | | | | | |
| | ១.៣.២. ចំនួនស្ពានឈើ | | | | | | |
| | ១.៣.៣. ចំនួន ទ្វារទឹក | ២ | កន្លែង | ១ | ១ | ០ | |
| | ១.៣.៤. ចំនួនលូឆ្លងផ្លូវ | ១០ | កន្លែង | ៣ | ៣ | ៤ | |
| | ១.៣.៥. ស្ពានបង្ហៀរ | ១ | កន្លែង | ០ | ១ | ០ | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | | | | | | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | ៤ | អាគារ | ១ | ១ | ២ | |
| | ២.៦.១.២.៤. សាលាមធ្យមសិក្សា | ១ | អាគារ | - | - | ១ | |
| | ២.៦.១.២.៥. សាងសង់ស្នាក់ការសហគមន៏នេសាទ | | | | | | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២.៦.១.៤. មណ្ឌលសុខភាព | | | | | | |
| | ២.៦.១.៥. ប៉ុស្តិសុខភាព | ១ | អាគារ | - | - | ១ | |
| | ២.៦.១.៦. ស្រះទឹកស្អាត | ៨ | ស្រះ | ២ | ៣ | ៣ | |
| | ២.៦.១.៧. អណ្តូងទឹកស្អាត | ៨០ | អណ្តូង | ៣០ | ៣០ | ២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.១.៨. កន្លែងចាក់សំរាម | ១ | កន្លែង | - | - | ១ | |
| | **២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៤.១. ប៉ុស្តិ៍នគរបាល | | | | | | |
| | ២.៦.១.៤.២. ទីតាំងផ្សារ | ១ | កន្លែង | ១ | - | - | |
| | **២.៦.១.៥. កន្លែងគោរពបូជា** | | | | | | |
| | ២.៦.១.៥.១. ទីកន្លែងសាការៈបូជា | | | | | | |
| | ២.៦.១.៥.២. វត្តព្រះអារាម | | | | | | |
| | ២.៦.១.៥.៣. សាលាឆទាន | | | | | | |
| ២.៦.២. | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | **២.៦.២.១. គំរោងប្រើប្រាស់ដីតាមវិស័យធំៗ** | | | | | | |
| | ២.៦.២.១.១. ដីឡូតិ៍នៃសាទ | | | | | | |
| | ២.៦.២.១.២. ដីសហគមន៍ប្រើប្រាស់ទឹក (កសិកម្ម) | ១៤,៩៦ | ម៉ែត្រការ៉េ | | | | បឹង,ត្រពាំង |
| | ២.៦.២.១.៣. ដីអភិរក្សជលផលដីរនាត | | | | | | |
| | ២.៦.២.១.៤. ដីកន្លែងអភិរក្សសត្វស្លាបដីរនាត | | | | | | |
| | ២.៦.២.១.៥. ដីតំបន់ប្រើប្រាស់ច្រើនយ៉ាង | | | | | | |
| | ២.៦.២.១.៦. ដីសម្បទានសង្គមកិច្ច | | | | | | |
| | **២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-ឃុំ** | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.២.២.១. ដីភូមិ | ៩២ | ហត | ៣០ | ៣០ | ៣២ | |
| | ២.៦.២.២.២. ដីវាលកប់ខ្មោច | | | | | | |
| | ២.៦.២.២.៣. ដីវាលស្រែ | ២០០ | ហត | ៥០ | ៧៥ | ៧៥ | |
| | ២.៦.២.២.៤. ដីស្រោចស្រព | ៥០ | ហត | ១០ | ២០ | ២០ | |
| | ២.៦.២.២.៥. ដីចំការដំណាំរយៈពេលខ្លី | ៥ | ហត | ១ | ២ | ២ | |
| | ២.៦.២.២.៦. ដីចំការដំណាំឈើហូបផ្លែ | | | | | | |
| | ២.៦.២.២.៧. ផ្សេងៗ | | | | | | |
| | **២.៦.២.៣. គំរោងផ្នែកបង្កើនជំនាញ និងមុខរបរ** | | | | | | |
| | ២.៦.២.៣.១. វគ្គបណ្តុះបណ្តាលអំពីការធ្វើស្រែបង្កើនរដូវ | ១៥០ | គ្រួសារ | ៥០ | ៥០ | ៥០ | |
| | ២.៦.២.៣.២. វគ្គបណ្តុះបណ្តាល អំពីការប្រើប្រាស់ជី | ៩០០ | គ្រួសារ | ៣០០ | ៣០០ | ៣០០ | |
| | ២.៦.២.៣.៣. វគ្គបណ្តុះបណ្តាល អំពីការកែប្រែគុណភាពដី | ១៥០០ | គ្រួសារ | ៥០០ | ៥០០ | ៥០០ | |
| | ២.៦.២.៣.៤. ... | | | | | | |
| | | | | | | | |

# ផែនទីប្រើប្រាស់ដីពេលអនាគត ឃុំនគរភាស ឆ្នាំ ២០០៩ ~ ២០២២

## Future Land Use Map of Norkpr Phease Commune for Year 2009 - 2022 (170105)



# ផែនទីគំរបព្រៃឈើឆ្នាំ២០០២នៅឃុំនគរគោស



ឧបសម្ព័ន្ធទី៥: រូបភាពក្រុមការងារគាំទ្រការរៀបចំផែនការប្រើប្រាស់ដី និងសកម្មភាពក្រុមប្រឹក្សាឃុំ នគរភាស ស្រុកអង្គជុំ



កិច្ចប្រជុំផ្លាស់ប្តូរបទពិសោធន៍ការអនុវត្ត CLUP



កិច្ចប្រជុំណែនាំ និង ត្រួតពិនិត្យការងារអនុវត្ត CLUP ពីថ្នាក់ជាតិ





កិច្ចប្រជុំថ្នាក់ឃុំស្តីពីការធ្វើបច្ចុប្បន្នភាពផែនទី





កិច្ចប្រជុំថ្នាក់ស្រុក ស្តីពីការកំនត់ព្រៃប្រទល់រដ្ឋបាលឃុំ

# អនុវត្តន៍ ដោយៈ
# ក្រុមប្រឹក្សាឃុំនគរភាស ស្រុកអង្គរជុំ

## គាំទ្របច្ចេកទេសដោយៈ
## ក្រុមសមាសភាគរៀបចំដែនដីថ្នាក់ខេត្តសៀមរាប

| | |
|---|---|
| ១. លោកៈ ប៊ូ ជុំសម្បត្តិ | ៈ ប្រធានក្រុមការងារ និង ជាអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី |
| ២. លោកៈ ម៉ៃ រ៉ុន | ៈ មន្ត្រីសំរបសំរួល និង ជាអនុប្រធានការិយាល័យសុរិយោដីខេត្ត |
| ៣. លោកៈ ជៀប ប៊ុនអៀង | ៈ ជំនួយការបច្ចេកទេសផែនការប្រើប្រាស់ដី និង ពត៌មានភូមិសាស្ត្រ |
| ៤. លោកៈ ឡូយវឌ្ឍនា | ៈ មន្ត្រី ពត៌មានភូមិសាស្ត្រ |
| ៥. លោកៈ ទុំ នទី | ៈ មន្ត្រី ពត៌មានភូមិសាស្ត្រ |
| ៦. លោកៈ ហង្សចិន្តា | ៈ មន្ត្រីកំនត់ព្រំ និង ជា អនុប្រធានការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុកប្រាសាទបាគង |

## សំរបសំរួលបច្ចេកទេសនៅមូលដ្ឋាន ដោយៈ
## ក្រុមផែនការប្រើប្រាស់ដី ស្រុកអង្គរជុំ

| | |
|---|---|
| ១. លោកៈ ហឿល សារួន | ៈ ប្រធានក្រុមផែនការប្រើប្រាស់ដីស្រុក និង ជា ប្រធានការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុកអង្គរជុំ |
| ២. លោកៈ ខៀងសារ៉ាត់ | ៈ អនុប្រធានក្រុមផែនការប្រើប្រាស់ដីស្រុក និង ជានាយរងសង្កាត់រដ្ឋបាលព្រៃឈើស្រុកអង្គរជុំ |
| ៣. លោកៈ ផន ម៉ា | ៈ សមាជិកក្រុម និងជា មន្ត្រីកសិកម្មស្រុកអង្គរជុំ |
| ៤. លោកៈ ភន់ សុខន | ៈ សមាជិកក្រុម និងជា មន្ត្រីធនធានទឹក ស្រុកអង្គរជុំ |